# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ជូនសពលោកវរសេនីយ៍ឯក **ឡុង គោគ** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៣១១៨

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤២ ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឯកឧត្តម **ឈុប នរិទ្ធ** ជាឧត្តមសេនីយ៍ត្រី ក្នុងឋានន្តរស័ក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៣១១៩

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៣ ស្តីពី ការតែងតាំងឯកឧត្តម **ស៊ាង ថៃ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **កែ សុវណ្ណា** ដែលបានទទួលភារកិច្ចថ្មី ៣១២០

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៤ ស្តីពី ការតែងតាំងឯកឧត្តម **សៅ វ៉ានី** ជាអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ៣១២១

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៥ ស្តីពី ការតែងតាំងលោក **មាស សុទ្ធុឡិឌី** ជាឧកញ៉ា ៣១២២

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **យ៉ូ ឌី** (YU DI) ជនជាតិចិន សញ្ជាតិចិន ៣១២៣

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ៊ូ អ៊ី** (HU YI) ជនជាតិចិន សញ្ជាតិចិន ៣១២៤

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ M. Benoît Duchâteau-Arminjon ៣១២៥

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៥២ ស្តីពី ការតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ចំនួន ១៦ រូប ជាបណ្ឌិតសភាចារ្យស្ថាបនិក ៣១២៦

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៥៣ ស្ដីពី ការតែងតាំងឯកឧត្ដម **សេខ ឈួន** ជា អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ៣១២៨

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/២៥៤ ស្ដីពី ការតែងតាំងឯកឧត្ដម **គង់ ដួង** ជា ទីប្រឹក្សាក្រសួង ព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៣១២៩

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/២៥៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៥ រូប ៣១៣០

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/២៥៦ ស្ដីពី ការដាក់មន្ត្រីរាជការ ០៤ រូប របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឱ្យចូលនិវត្តន៍ ៣១៣២

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៥៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម អស់លោក និងលោកស្រី ចំនួន ២១ រូប ៣១៣៣

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៥៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្ដម និងអស់លោក ចំនួន ០៣ រូប ៣១៣៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៣-៤-២០១៥ -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្ដីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ៣១៣៥

០៣-៤-២០១៥ -អនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៣១៧៥

០៣-៤-២០១៥ -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៣១៧៧

០៣-៤-២០១៥ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៣១៧៩

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣១៨១

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣១៨២

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៤ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៣១៨៤

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣១៨៦

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣១៨៨

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៣១៨៩

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣១៩០

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣១៩២
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣១៩៣
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣១៩៤
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពី ការធ្វើសមាហរណកម្មឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិកម្ពុជា ទៅក្នុងឋានន្តរស័ក្តិ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៣១៩៥
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន ៣១៩៨
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៣២០០
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣២០១
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការចូលនិវត្តន៍ ៣២០៣
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពី ការកែសម្រួលសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា ៣២០៦
២៧-៣-២០១៥ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣២០៨

## ២_សារាចរណែនាំ

០៣-៤-២០១៥ -សារាចរណែនាំលេខ ០២ សរណន ស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០១៦ ៣២១៩

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៧-០១-២០១៥ -ប្រកាសលេខ ០២៩ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វឹស ហ្គាវ័ន្ត អឺភើរីល (ខេមបូឌា) បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៣២៣៦
០៤-០២-២០១៥ -ប្រកាសលេខ ០៣៣ ឧស.កឧ.ប្រក.០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្សុងយី ផៅវ័រ អេឃ្វីបម៉ិន បង្កើតរោងចក្រផលិត បរិក្ខារអគ្គិសនី ៣២៤០
១២-០២-២០១៥ -ប្រកាសលេខ ០៥១ ឧស.កឧ.ប្រក.០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីង បាយអូថេក (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រផលិត គ្រឿងសង្ហារឹមសម្រាប់ ការិយាល័យ (ពីឈើ), គ្រឿងសង្ហារឹមសម្រាប់ផ្ទះ (ពីឈើ) និងសម្ភារៈផ្សេងៗ (ពីឈើ) ៣២៤៤

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សេត អាត អាឃីតេក ខូ អិលធីឌី** ៣២៤៧

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣០៣ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ប៊ីឌីខេឆេល ខូ អិលធីឌី** ៣២៤៩

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣០៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើត សាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី "សាខាស្រុកព្រៃនប់-ឃុំវាលរេញ"** ៣២៥១

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣០៨ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើត សាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី "សាខាស្រុកកូនមុំ-ឃុំត្រពាំងច្រេស"** ៣២៥២

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វីហ្គ្រូវ ផៅវ័រ ផ្លាស** ៣២៥៣

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣១១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស្កាយ ណាយ II អ៊ិនធើណេសិនណល** ៣២៥៥

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០៣១៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឆាយណា ស៊ីនសៀរលី លេឌើរ គ្រុប (ខេមបូឌា) លីមីធីត** ៣២៥៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤១

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនសពលោកវរសេនីយ៍ឯក **ឡុង ភោគ** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣១ខ.១៥០៣.២៤៤

លេខ: ៤២៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សមូហោភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ  នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣  ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ  ០២/នស/៩៤  ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤  ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ  ០៦/នស/៩៤  ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ  ១៩៩៤  ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ  នស/រកម/០១៩៦/០៨  ចុះថ្ងៃទី  ២៤ ខែ មករា ឆ្នាំ  ១៩៩៦  ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០  ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** - ផ្ទេរក្របខ័ណ្ឌឯកឧត្តម **ណុប  នរិន្ទ** ពីឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ

- តែងតាំងឯកឧត្តម **ណុប  នរិន្ទ**  ជា **ឧត្តមសេនីយ៍ត្រី** អត្តលេខ **៧៥៧៦៩** ក្នុងឋានន្តរស័ក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន  សែន**  នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ   ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣១  ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស.១៥០៣.២៤៥

លេខៈ ២៦២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី០៣ ខែមេសាឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ស៊ាង ថៃ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **កែ សុខណ្ណ** ដែលបានទទួលភារកិច្ចថ្មី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៤៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពាណ.១៥០៣.២៤៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **សៅ រ៉ាវី** ជាអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ ៧៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ចរស.១៥០៣.២៤៧

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

លោក **មាស សុទ្ធវិជ្ជី**

ជា

**ឧកញ៉ា**

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ៣៥៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពរស.១៥០៣.២៤៥

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ូ ឌី** ( YU DI ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៣ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **យូ ពិសិដ្ឋ** ( YU PISETH ) ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ជករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស.១៥០៣.២៤៩

លេខ: ៧៦០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ៊ូ អ៊ី** ( HU YI ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៣ នៅខេត្តជាំងហ៊ូ សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **ប្រ៊ៃ អ៊ីហ៊ូ** ( BRICE YI HU )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរស.១៥០៣.២៥០

លេខ: ៧ ៥ ៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៨៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

**M. Benoît Duchâteau-Arminjon**

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៤៧១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣.ស.ល. ១៥០៣.២៥១

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៧

## យើង

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ចំនួន១៦រូប ជា **បណ្ឌិតសភាចារ្យស្ថាបនិក** : ដូចមានរាយនាមខាងក្រោម៖

១-សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន**
២-ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន**
៣-លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា**
៤-ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ិន សំណាង**
៥-ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**

៦-ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន
៧-ឯកឧត្តមបណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ
៨-ឯកឧត្តមបណ្ឌិតសភាចារ្យ គិច សំណាង
៩-ឯកឧត្តមបណ្ឌិតសភាចារ្យ ជា ណេង
១០-ឯកឧត្តមបណ្ឌិតសភាចារ្យ សំ សោភាន់
១១-ឯកឧត្តមបណ្ឌិតសភាចារ្យ សោម សុមុនី
១២-ឯកឧត្តមបណ្ឌិតសភាចារ្យ ខៀវ ថរិកា
១៣-ឯកឧត្តមបណ្ឌិតសភាចារ្យ ឆយ អូន
១៤-លោកបណ្ឌិតសភាចារ្យ ឃីង ហុកឌី
១៥-លោកបណ្ឌិតសភាចារ្យ ម៉ក់ ភឹន
១៦-លោកបណ្ឌិតសភាចារ្យ ប៉ោង ផែល

**មាត្រា២ .-**

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៥

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

នស.១៥០៣.២៥៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៤៦១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **សេង ឈួន** ជា**អនុរដ្ឋលេខាធិការ** ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៤៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣រល.១៥០៣.២៥៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សមូហោភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **គង់ ដួង** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស.១៥០៣.២៥៧

លេខៈ ២៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **រស់ សុខសំបូរ** អត្តលេខ ០៥៨៨៩
២- លោកវរសេនីយ៍ឯក **យុន ឧុឡារី** អត្តលេខ ០៥០១៥
៣- លោកវរសេនីយ៍ឯក **ឱុន ពិសិដ្ឋ** អត្តលេខ ០៦៣៨១
៤- លោកវរសេនីយ៍ឯក **ប៉ាង ណារិទ្ធ** អត្តលេខ ០១០០៥
៥- លោកវរសេនីយ៍ឯក **សាន សុទ្ធី** អត្តលេខ ០៤៨៤២
៦- លោកវរសេនីយ៍ឯក **គាន គីមលាង** អត្តលេខ ៥៤៨០៦
៧- លោកវរសេនីយ៍ឯក **សុខ ឆាសនា** អត្តលេខ ០៣៥៩៧
៨- លោកវរសេនីយ៍ឯក **សោម ឃាភាន** អត្តលេខ ០១៥៣០
៩- លោកវរសេនីយ៍ឯក **ខេង រ៉ា** អត្តលេខ ១០៥៤៥
១០- លោកវរសេនីយ៍ឯក **ឃិន ប្រសិទ្ធ** អត្តលេខ ០២១៥៨
១១- លោកវរសេនីយ៍ឯក **ជួប សំបូរ** អត្តលេខ ០១៤៥៨

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១២- លោកវរសេនីយ៍ឯក **គុជ គន្ធថេន** អត្តលេខ ០៦៧៦៨

១៣- លោកវរសេនីយ៍ឯក **ឡុង ធូ** អត្តលេខ ១១២០៥

១៤- លោកវរសេនីយ៍ឯក **សូ ម៉ាន់ឌី** អត្តលេខ ០២៤២៣

១៥- លោកវរសេនីយ៍ឯក **គីម សុទ្ធី** អត្តលេខ ១៣១១៦ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស.១៥០៣.២៥៥

លេខ: ៥៧៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/២៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដាក់មន្ត្រីរាជការ ០៤ រូប របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល :

១- ឯកឧត្តម **ហង្ស ប៊ុណ្ណាក់** ឧត្តមមន្ត្រី ថ្នាក់លេខ ៣ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៥
២- ឯកឧត្តម **ជី ស៊ីថា** ឧត្តមមន្ត្រី ថ្នាក់លេខ ៣ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៥
៣- លោក **ជាម សុផល** ឧត្តមមន្ត្រី ថ្នាក់លេខ ៣ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៥
៤- លោក **សរ សាមេធា** ឧត្តមមន្ត្រី ថ្នាក់លេខ ២ ចូលនិវត្តន៍ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣១ស.១៥០៣.២៥៩

**ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ [illegible] ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

## ជូន

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

ឯកឧត្តម អ៊ុំ សុថា

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ស៊ុម | ស៊ីថា | ២-លោក | ឡុង | ណារ៉ូ |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | កែវ | សុវណ្ណរិទ្ធ | ៤-លោក | សំរិទ្ធ | សុវិឌ្យា |
| ២-លោក | ជា | វិសុទ្ធ | ៥-លោក | ចាន់ | ពិសិដ្ឋ |
| ៣-លោក | រស់ | គីមលាង | ៦-លោកស្រី | ចិន | ចន្ទ្រា |

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា**

| | | | | | |
|---|---|---|---|---|---|
| ១-លោកស្រី | អឿន | ណារី | ៤-លោក | ឱម | អដ្ឋរស |
| ២-លោក | ម៉ា | ណូរ៉ាទីន | ៥-លោក | ជា | សតិភទ្ទ |
| ៣-លោក | គីម | អេងឡុយលួង | | | |

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | ឈន | ឆាន | ៥-លោក | ហាក់ | ឋុឡឺ |
| ២-លោក | សេក | សំអាន | ៦-លោក | អ៊ូ | គុណវឌ្ឍន៍ |
| ៣-លោក | ផេង | ធី | ៧-លោក | ចៅ | ពេជ្រសង្វារ |
| ៤-លោក | អាំង | សោភ័ណ្ឌ | | | |

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*
*ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាក់បង្គាប់*
ប្រមុខរដ្ឋស្តីទី

៣រល.១៥០៣.២៦០

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ២៦៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **ច័ន្ទ សុវណ្ណារ៉េត**
២- ឯកឧត្តម **មាស សំណាង**
៣- លោក **សាយ រស្មី**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស.១៥០៣.២៦១

លេខ: ៤៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានា៖

- គុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នៃនគរូបនីយកម្ម
- ការការពារសិទ្ធិនិងផលប្រយោជន៍សាធារណៈនិងឯកជន ក្នុងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- ការលើកកម្ពស់តម្លៃវប្បធម៌ ការអភិវឌ្ឍបៃតង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ព្រមទាំងបង្កើនការបង្ការនិងការទប់ស្កាត់គ្រោះមហន្តរាយ
- ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួល សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងកុមារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន នៅព្រះរាជាណាចក្រកម្ពុជាឲ្យមាន៖

- មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា កន្លែងលំហែកម្សាន្ត និងការធ្វើចរាចរណ៍ ប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល
- ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការពារបរិស្ថាន ការពារជាតិ សន្តិសុខស្បៀង និងការថែរក្សា សម្បត្តិវប្បធម៌
- ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈរាជធានី ក្រុង និងទីប្រជុំជន
- តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងទីក្រុងនិងជនបទ ដោយផ្អែកលើធាតុភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ការតម្រង់ទិសច្បាស់លាស់ដែលអាចដឹងមុនបាននូវការអភិវឌ្ឍនៅរាជធានី ក្រុង និងទីប្រជុំជន

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ព្រមទាំងដីរបស់បុគ្គលឯកជនក្នុងរាជធានី ក្រុង និងទីប្រជុំជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់អភិរក្សពិសេសដែលមានចែងដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានពន្យល់ក្នុងសទ្ទានុក្រមភ្ជាប់ជាឧសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## គោលការណ៍

**មាត្រា៥ .-**

កិច្ចការនគរូបនីយកម្មត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទូទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុងជាមូលដ្ឋានបង្អែក សម្រាប់ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌។

## ជំពូកទី៣
## យន្តការ សមត្ថកិច្ច និងភារកិច្ច

**មាត្រា៦ .-**

យន្តការសម្រាប់ធ្វើផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានដូចតទៅ៖

១- នៅថ្នាក់ជាតិ មានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដែលត្រូវផ្តួចផ្តើមរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិនិងនៅតាមតំបន់។

២- នៅថ្នាក់ក្រោមជាតិ រួមមាន៖

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ដែលត្រូវផ្តួចផ្តើមរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ស្រុក ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខណ្ឌ ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវផ្តួចផ្តើមរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់។

យន្តការនៅថ្នាក់ក្រោមជាតិដែលបានរៀបរាប់ខាងលើត្រូវធ្វើការសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការរៀបចំផែនការរូបវន្តទីក្រុង។

**មាត្រា៧ .-**

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិបានកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិនិងព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៩នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា៨ .-**

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ដោយអនុក្រឹត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩ .-**

យន្តការ សមត្ថកិច្ច ភារកិច្ច និងនីតិវិធី សម្រាប់រៀបចំផែនការប្រើប្រាស់ដី ឃុំ សង្កាត់ បានកំណត់ដោយអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់។

## ជំពូកទី៤
## ផែនការរូបវន្តនិងនីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង
### ផ្នែកទី១
### ផែនការរូបវន្តទីក្រុង

**មាត្រា១០ .-**

ផែនការរូបវន្តទីក្រុងរួមមាន៖

១- ប្លង់គោលប្រើប្រាស់ដី

២- ផែនការប្រើប្រាស់ដី

៣- ប្លង់លម្អិតនគរូបនីយកម្ម។

**មាត្រា១១ .-**

ប្លង់គោលប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ។

២- ការកំណត់ចក្ខុវិស័យ : ត្រូវសិក្សានិងកំណត់ចក្ខុវិស័យអភិវឌ្ឍនិងអភិរក្ស សម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំចំពោះថ្នាក់ក្រុង ស្រុក ខណ្ឌ និងយ៉ាងតិច២០(ម្ភៃ)ឆ្នាំចំពោះថ្នាក់រាជធានី។

៣- ការកំណត់យុទ្ធសាស្ត្រៈ ត្រូវសិក្សានិងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្ស ដើម្បីសម្រេចបាននូវចក្ខុវិស័យមានៈ

- យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សទីក្រុង
- យុទ្ធសាស្ត្រប្រើប្រាស់ដី
- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច
- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច
- យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងកាកសំណល់
- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ។

៤- គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដីមានដូចជាៈ

៤.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់និន្នាការនៃការពង្រីកនៃទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៤.២- ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យ មានដូចជាៈ

- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់គម្រោងពង្រីកទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៥- សេចក្តីណែនាំអនុវត្តនិងគ្រប់គ្រងការអភិវឌ្ឍ : ត្រូវរៀបចំបញ្ជីគម្រោងនិងផែនការសកម្មភាពតាមលំដាប់អាទិភាព សម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងសេចក្តីណែនាំសម្រាប់ការអនុវត្តនិងការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។

៦- ឯកសារឧបសម្ព័ន្ធ។

៧- ឯកសារទាំងអស់ ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស។

ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុង ផ្ដោតតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

ប្លង់គោលប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ប្លង់គោលប្រើប្រាស់ដីក្រុងនិងទីប្រជុំជន ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១២ .–**

ផែនការប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : មានជាអាទិ៍ទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់លំនៅឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ធនធានធម្មជាតិ ផែនទី និងរូបភាព។

២- ការកំណត់យុទ្ធសាស្ត្រ : ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោល។

៣- គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដីមានដូចជា៖

៣.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់កំណត់តំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ផ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៣.២- ប្លង់អនាគតកាលមានដូចជា៖

- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកតំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ផ្លាតម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៤- បទបញ្ញាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

៥- ឯកសារនិងឧបសម្ព័ន្ធ។

ផែនការប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ផែនការប្រើប្រាស់ដីក្រុង ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៣ .-**

ប្លង់លម្អិតនគរូបនីយកម្មមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ផ្អែកតាមទិន្នន័យប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

២- គំនូសប្លង់លម្អិតនគរូបនីយកម្មមានដូចជា៖

- ប្លង់បង្ហាញពីទីតាំង
- ប្លង់សរុប ដោយមានកំណត់ព្រំប្រទល់
- ប្លង់លម្អិតការប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ផ្លាតគម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់
- ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ
- ប្លង់នេត្រាទស្សន៍ឬគំរូសំណាក។

ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

## ផ្នែកទី២
## នីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង

**មាត្រា១៤ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៦០(ហុកសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ និងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាបសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវពិនិត្យ ផ្តល់ការឯកភាព និងផ្ញើសំណើសុំការសម្រេចចុងក្រោយពីរាជរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)

ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែងដែលត្រូវបាន កំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៥ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងនិងប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៦ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការនិងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈ

រយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះអាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប) ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួល សេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិង នគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយគណៈកម្មាធិការ រៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៧ .–**

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវគោរពតាមគោលការណ៍ដូចមានចែង ក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវ ស្ថានភាពវិវត្តរបស់ទីក្រុង ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីនិងផែនការ ប្រើប្រាស់ដី សម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈ ដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីនៅទីក្រុងដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តទៅ បានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីដែលបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឲ្យប្រើប្រាស់ជា ផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីដែរ។

ក្នុងករណីដែលទីប្រជុំជនមានទីតាំងស្ថិតនៅលើតំបន់ប្រសព្វរវាងរដ្ឋបាលថ្នាក់ក្រោមជាតិពីរឬច្រើន រដ្ឋបាល ថ្នាក់ក្រោមជាតិទាំងនោះត្រូវសហការគ្នារៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅតំបន់នោះ។

**មាត្រា១៨ .–**

សេចក្តីណែនាំបច្ចេកទេសនិងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង និងប្លង់លម្អិតនគរូបនីយកម្ម ព្រមទាំងវិធីដោះស្រាយការតវ៉ាផ្សេងៗ ត្រូវកំណត់ដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

## ជំពូកទី៥
## បទប្បញ្ញត្តិនៃការប្រើប្រាស់ដី

**មាត្រា១៩ .–**

ប្រព័ន្ធផែនការប្រើប្រាស់ដីនៅទីក្រុងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា២ប្រភេទ រួមមាន៖

១- ប្រភេទដីអាចសាងសង់បាន

២- ប្រភេទដីកម្រិតការសាងសង់។

## ផ្នែកទី១
## អំពីប្រភេទដីអាចសាងសង់បាន

**មាត្រា២០ .-**

ប្រភេទដីអាចសាងសង់បាន ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់លំនៅឋាន រួមមាន៥(ប្រាំ)ប្រភេទ៖

- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប(ផ្ទះ ភូមិគ្រឹះ ឬពាក់កណ្តាលភូមិគ្រឹះ)
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប(ផ្ទះល្វែងឬផ្ទះជាប់គ្នា)
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យម
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- តំបន់លំនៅឋានចម្រុះ។

២- តំបន់ពាណិជ្ជកម្ម រួមមាន២(ពីរ)ប្រភេទ៖

- តំបន់ពាណិជ្ជកម្ម
- តំបន់ពាណិជ្ជកម្មចម្រុះ។

៣- តំបន់ឧស្សាហកម្ម រួមមាន៣(បី)ប្រភេទ៖

- តំបន់ឧស្សាហកម្ម
- តំបន់ឧស្សាហកម្មស្រាល
- តំបន់ឧស្សាហកម្មចម្រុះ។

៤- តំបន់ចម្រុះ

៥- តំបន់ដឹកជញ្ជូន

៦- តំបន់ទេសចរណ៍

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ

៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង

៩- តំបន់វប្បធម៌និងសាសនា

១០- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ការបែងចែកតំបន់ក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២១ .-**

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយសម្រាប់ប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

១- តំបន់លំនៅឋាន៖

| | |
|---|---|
- ការដ្ឋានសាងសង់ដែលប្រើគ្រឿងចក្រ បរិក្ខារលើកស្ទូច ហើយធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ឬមិនបានបំពាក់ភ្លើងសញ្ញាសំគាល់នៅពេលយប់

- ការបង្ហូរទឹកបេតុងពីរថយន្តដឹកបេតុងឬពីរថយន្តបូមបេតុង និងទឹកស៊ីម៉ងត៍ដែលបានបង្ហូរចេញពីការដ្ឋានសាងសង់លើចិញ្ចើមផ្លូវថ្នល់ លូសាធារណៈ និងទីតាំងសាធារណៈ
- ការដ្ឋានសាងសង់ដែលគ្មានអ្នកបច្ចេកទេស ឬវិស្វករ ឬស្ថាបត្យករ ជាអ្នកគ្រប់គ្រងនិងទទួលខុសត្រូវ
- ខកខានមិនបានរុះរើ សំអាតនិងអនុវត្តតាមសេចក្តីជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៧៨ .-**

ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ដែលមានវិញ្ញាបនបត្រប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ផុតសុពលភាព ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត៣។

**មាត្រា៧៩ .-**

រាជធានីខេត្តមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការនិងរាចសុំឲ្យរឹបអូសសម្ភារៈ បរិក្ខារ ឧបករណ៍ផ្សេងៗទៀត ដោយអនុលោមតាមនីតិវិធីជាធរមាន ក្នុងករណីបុគ្គលដែលត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៨០ .-**

មន្ត្រីមានសមត្ថកិច្ចណាដែលប្រកែកមិនព្រមទទួលពិនិត្យលើសំណុំលិខិតស្នើសុំការអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ដោយគ្មានមូលហេតុត្រឹមត្រូវដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ ប្រសិនបើមាន។

សមត្ថកិច្ចជំនាញនគរូបនីយកម្មនិងសំណង់ឬមន្ត្រីដែលមានភារកិច្ចចុះត្រួតពិនិត្យការដ្ឋានសំណង់ ដែលពុំបានជំទាស់ទៅលើការអភិវឌ្ឍអចលនវត្ថុដែលមិនស្របទៅនឹងលិខិតអនុញ្ញាតសាងសង់ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌប្រសិនបើមាន។

ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល ចំពោះមន្ត្រីជំនាញណាដែលចុះទៅត្រួតពិនិត្យការដ្ឋានសាងសង់ ជួសជុល ឬរុះរើ ដោយគ្មានលិខិតបញ្ជាបេសកកម្ម។

## ជំពូកទី១១
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៨១ .-**

រាល់ការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ការចេញវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវផ្នែកនគរូបនីយកម្មនិងសំណង់ ការចេញលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ការចេញលិខិតបិទការដ្ឋានសាងសង់ និងការផ្តល់លិខិតអនុញ្ញាតគោលការណ៍បច្ចេកទេសលើការអភិវឌ្ឍអចលនវត្ថុនិងការសាងសង់ សេវាបច្ចេកទេសសាងសង់ ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់ ត្រូវតែបង់កម្រៃសេវានគរូបនីយកម្មនិងសំណង់។

ការគណនាតម្លៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវឈរលើមូលដ្ឋាននៃទំហំផ្ទៃក្រឡាដី ទំហំផ្ទៃក្រឡាសំណង់ និងសន្ទស្សន៍ប្រើប្រាស់ដី និងសំណង់នៃគម្រោងទាំងមូល។

តម្លៃសោហ៊ុយសេវានិងមូលដ្ឋានសម្រាប់គណនា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៨២ .-**

ចំណូលកម្រៃសេវាដូចមានចែងក្នុងមាត្រា៦១ខាងលើនេះ ត្រូវបែងចែកមួយផ្នែកចូលថវិការដ្ឋ មួយផ្នែកសម្រាប់គាំទ្រការងារបច្ចេកទេសនគរូបនីយកម្មនិងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មួយផ្នែកទៀតសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

ការបែងចែកចំណូលបានមកពីកម្រៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៨៣ .-**

ការប្រើប្រាស់ដីឬអគារដែលកើតមានមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបានអនុញ្ញាតឲ្យបន្តការប្រើប្រាស់តាមលក្ខខណ្ឌមានស្រាប់នាពេលបច្ចុប្បន្ន ក្នុងករណីដែលមិនបង្កគ្រោះថ្នាក់ឬមហន្តរាយដល់សុខុមាលភាពសាធារណៈ សុវត្ថិភាពសាធារណៈ បរិស្ថាន ប្រវត្តិសាស្ត្រ និងវប្បធម៌។

**មាត្រា៨៤ .-**

លក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យនេះនឹងត្រូវយកទៅអនុវត្តចំពោះតែប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្មដែលបានរៀបចំក្រោយពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម ដែលកំពុងដំណើរការរៀបចំនិងបានរៀបចំហើយ ប៉ុន្តែមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់ ត្រូវបានអនុញ្ញាតឲ្យបន្តរៀបចំបញ្ចប់និងដាក់ស្នើសុំការអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ ជាប្លង់បឋមដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវខិតខំជំរុញការរៀបចំបន្តបញ្ចប់ និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូប-នីយកម្ម នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលបានដាក់ស្នើសុំលិខិតអនុញ្ញាតមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តនីតិវិធីស្នើសុំ ដោយអនុលោមតាមនីតិវិធីដែលបានធ្វើពីមុន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលកំពុងដំណើរការអភិវឌ្ឍនិងសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តដំណើរការសាងសង់ ស្របតាមលិខិតអនុញ្ញាតដែលបានចេញជូនម្ចាស់សំណើ។

លិខិតអនុញ្ញាតឲ្យអភិវឌ្ឍអចលនវត្ថុ ដែលបានចេញជូនម្ចាស់សំណើមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តសុពលភាពអនុវត្តរហូតដល់អស់សុពលភាព។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៨៥ .-**

បទប្បញ្ញត្តិដែលមានអានុភាពនៅពេលដែលអនុក្រឹត្យត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងអនុក្រឹត្យនេះ។

**មាត្រា៨៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន

### សន្ទានុក្រម

**ការអភិវឌ្ឍដី** សំដៅដល់ការប្តូរប្រភេទនៃការប្រើប្រាស់ដីទៅជាប្រភេទមួយផ្សេងទៀត តាមរយៈការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែទម្រង់ដី និងការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដី សម្រាប់គោលដៅនៃការសាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ការបង្រួមក្បាលដី** សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឲ្យក្លាយទៅជាក្បាលដីតែមួយ ដើម្បីធ្វើផែនការអភិវឌ្ឍទីក្រុង សម្រាប់ធ្វើសមាហរណកម្មនិងធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សេវាសាធារណៈ សំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។

**ការបំបែកក្បាលដី** សំដៅដល់ការបំបែកក្បាលដីតែមួយទៅជាក្បាលដីច្រើន សម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ការកែសម្រួលក្បាលដី** សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការប្តូរប្រភេទនៃការប្រើប្រាស់ដី** សំដៅដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**តំបន់លំនៅឋានដាច់គ្នាកម្ពស់ទាប** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នា ឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាប ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានឆ្លាតម្លាតជុំវិញ អគារស្នាក់នៅ អាគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានជញ្ជាំងជាប់គ្នាដែលមានកម្ពស់ទាប ដូចជា ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានកម្ពស់មធ្យម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យម ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានកម្ពស់ខ្ពស់** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ ដូចជា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំនៅឋានចម្រុះ:** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានច្រើនប្រភេទ ដូចជាលំនៅឋានជាប់គ្នា លំនៅឋានពាក់កណ្ដាលជាប់គ្នា លំនៅឋានដាច់ពីគ្នា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ពាណិជ្ជកម្ម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានា ដូចជាអគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ។ល។ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ពាណិជ្ជកម្មចម្រុះ:** សំដៅដល់តំបន់ដែលមានមុខងារពាណិជ្ជកម្ម សម្រាប់បម្រើដល់លំនៅឋាននិងការស្នាក់នៅ មានដូចជាហាងលក់ដូរនិងទីផ្សារតូចៗដែលលក់ដូរទំនិញនិងសេវាកម្ម ដើម្បីផ្គត់ផ្គង់និងគាំទ្រដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានប្រចាំថ្ងៃ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ឧស្សាហកម្ម** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំដែលមានជាតិពុលខ្ពស់ ដូចជារោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំង យានដ្ឋាន ។ល។ ហើយមិនអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះឡើយ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ឧស្សាហកម្មស្រាល** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតតូចដែលមានជាតិពុលតិច ឬ មធ្យម ដូចជារោងចក្រ រោងសិប្បកម្មខ្នាតតូច ឃ្លាំង យានដ្ឋាន។ល។ ហើយអាចអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះបាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ឧស្សាហកម្មចម្រុះ:** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មនិងសេវាកម្ម។ គ្រប់អគាររោងចក្រទាំងអស់ត្រូវបានអនុញ្ញាតឲ្យសាងសង់ លើកលែងតែអគារដែលមានផលប៉ះពាល់បរិស្ថានខ្ពស់។ តំបន់នេះអាចអនុញ្ញាតឲ្យមានលំនៅឋាននិងអគារពាណិជ្ជកម្ម ដូចជា សាលារៀន មន្ទីរពេទ្យ សាកលវិទ្យាល័យ ភោជនីយដ្ឋាន រោងកុន ឃ្លាំង យានដ្ឋាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ចម្រុះ:** សំដៅដល់តំបន់ដែលអាចប្រើប្រាស់ពហុមុខងារ សម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្ម ដោយធានាបានបរិស្ថានរស់នៅ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ដឹកជញ្ជូន** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍ជាអាទ៍ ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផ កំពង់ផែ ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញ និងអគារ[illegible] មជ្ឈមណ្ឌលទូរគមនាគមន៍។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដី កំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ទេសចរណ៍** សំដៅតំបន់សម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍ និងកម្សាន្ត រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។

**តំបន់រដ្ឋបាលនិងសេវាសាធារណៈ** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈ ដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់លំហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់ សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់វប្បធម៌និងសាសនា** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ ដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនា ដូចជា ប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទាន ពុទ្ធិកសាកលវិទ្យាល័យ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់កសិកម្ម** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់វិស័យកសិកម្ម ដូចជាវាលស្រែ ចម្ការ សួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្តុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្គារ ក្តាម សិប្បកម្មបម្រើដល់កសិកម្ម ។ល។ តំបន់នេះអាចសាងសង់លំនៅឋានរបស់កសិករ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**តំបន់ព្រៃឈើ** សំដៅដល់តំបន់ផ្ទៃព្រៃឈើនិងគម្របព្រៃឈើ ដែលត្រូវការពារ ថែរក្សា និងដាំបន្ថែម ដូចជាព្រៃស្រោង ព្រៃរបោះ ព្រៃការពារ ព្រៃអភិរក្ស ព្រៃលិចទឹក។ល។

**តំបន់ធនធានទឹក** សំដៅដល់តំបន់ផ្ទៃទឹកនិងប្រភពទឹកដែលត្រូវថែរក្សានិងការពារ ដូចជាសមុទ្រ ទន្លេ ព្រែក ស្ទឹង អូរ ប្រឡាយ បឹង ទំនប់ សំណង់ធារាសាស្ត្រ។ល។

**តំបន់ការពារ** សំដៅដល់តំបន់ធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារ ដើម្បីបម្រើឲ្យវិស័យបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ ការអប់រំ និងការកម្សាន្ត ដូចជាឆ្នេរសមុទ្រ ចំណីទន្លេ ភ្នំឧទ្យានជាតិ តំបន់ដីសើម តំបន់ជីវធម្មជាតិ។ល។

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី(ប្រភេទដីអាចសាងសង់បាន និង ប្រភេទដីកម្រិតការសាងសង់)ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់ មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាព សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវ បានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយឬ ច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំ ការរចនាទម្រង់ រូបរាង និងសោភណភាព នៃរចនា សម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិត នគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ប្លង់ទ្រេត** សំដៅដល់ប្លង់សម្រាប់កំណត់កម្ពស់អតិបរមានៃសំណង់។ ប្លង់នេះត្រូវបានកំណត់ឡើងដោយ សមាមាត្រនៃទំហំទទឹងផ្លូវនិងការថយឆ្ងាតម្លាតនៃអគារជាមួយនឹងកម្ពស់អគារដើម្បីធានាឲ្យមានចរន្ត ពន្លឺ ចរន្តខ្យល់ និងបរិស្ថានរស់នៅល្អពីអគារមួយទៅអគារមួយទៀត ព្រមទាំងធានាភាពសុខដុមនីយកម្ម នៃស្ថាបត្យកម្មក្នុងតំបន់ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឲ្យមានការអភិវឌ្ឍនិងការសាងសង់លើ គ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់ លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិ សាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដី នេះ ត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេង ៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

**បទដ្ឋានទំហំដីឡូត៍បច្ចេកទេស** សំដៅដល់ទំហំដីឡូត៍ដែលកំណត់ដោយប្រវែងក្បាលដីនិងជម្រៅដី ហើយត្រូវ បានកំណត់ឡើង ដើម្បីធានាការរៀបចំ ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដី ឲ្យមានសោភណភាព មានសណ្តាប់ធ្នាប់។

**ផែនការរូបវន្តទីក្រុង** សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុង មានប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល ផែនការ ប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ ដីតំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដី និងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើ

សមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

ម្ចាស់សំណង់ សំដៅដល់ម្ចាស់សិទ្ធិលើអគារឬសំណង់។

ដង់ស៊ីតេប្រជាជន សំដៅដល់អនុបាតរវាងចំនួនប្រជាជននិងផ្ទៃក្រឡាដី ក្នុងវិសាលភាពជាក់លាក់ណាមួយ។

សំណង់សិល្បការ្យ សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀត ដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។

សន្ទស្សន៍ប្រើប្រាស់ដី សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ ដែលសំណង់នោះតាំងនៅ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ ស្របតាមសមត្ថកិច្ច។

មន្ត្រីមានសមត្ថកិច្ច សំដៅដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៥៥ ៩៤៤ ០០០ ០០០រៀល (ហាសិបប្រាំពាន់ប្រាំបួនរយសែសិបបួនលានរៀលគត់) ពីជំពូក៦៥ (ឧបត្ថម្ភកធន-ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦៥ (ឧបត្ថម្ភកធន-ឧបត្ថម្ភរាជធានី ខេត្ត) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភកធនដល់រាជធានី ខេត្ត ក្នុងឆ្នាំ២០១៥។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក៦០(ការទិញ) ចំនួន៧៥០ ០០០ ០០០រៀល មកជំពូក៦១ (សេវាកម្ម) ចំនួន៧៥០ ០០០ ០០០រៀល ជូនក្រសួងបរិស្ថាន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា២.**_

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងបរិស្ថានសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៤០០ ០០០ ០០០រៀល (បួនរយលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦០ (ការទិញ) ចំនួន ៧ ០០០ ០០០រៀល និងជំពូក៦១ (សេវាកម្ម) ចំនួន៣៩៣ ០០០ ០០០រៀល ជូនក្រសួងព័ត៌មាន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយរៀបចំកម្មវិធីសមោសរ វាង វិទ្យុនិងទូរទស្សន៍ខេត្តយូណាននិងទូរទស្សន៍ជាតិកម្ពុជា។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៨៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន១០រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវត្តពោធិអណ្តែត នៅភូមិបត់សិរមាន់ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម ៖

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **សោម** | **សុខា** | ៦-លោក | **ធិត** | **ស៊ាង** |
| ២-ឧបាសក | **ហួត** | **គីម** | ៧-លោក | **ធិន** | **សឿត** |
| ៣-ឧបាសិកា | **តាន់** | **ចិន** | ៨-អ្នកស្រី | **ស៊ុក** | **ចន្ថាទី** |
| ៤-ឧបាសិកា | **ហាក់** | **ឡឿន** | ៩-លោក | **អ៊ួន** | **ណុំ** |
| ៥-ឧបាសិកា | **ឡាក់** | **យ៉ី** | ១០-លោកអាចារ្យ | **នង** | **ណាន** |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

**សម្រេច**

**មាត្រា ១.**-ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសប្បុរសជន ចំនួន២០រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវត្តពោធិ៍អណ្តែត នៅភូមិបត់សិរមាន់ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ភើន ស៊ីណា** | គ្រូសូត្រស្តាំវត្តពោធិ៍អណ្តែត |
| ២-ព្រះតេជគុណ | **ញ៉ុក យន** | គង់នៅវត្តពោធិ៍លង្ការ ខេត្តសៀមរាប |
| ៣-លោកអាចារ្យ | **ម៉េង ឡាស** | សប្បុរសជន |
| ៤-ឧបាសក | **ជ័យ សម្បត្តិ** | សប្បុរសជន |
| ៥-ឧបាសក | **ឥន្ទ ស៊ីចាន់** | សប្បុរសជន |
| ៦-លោក | **សាយ កុយ** | នាយករងទីចាត់ការរដ្ឋបាលទូទៅ សាលាខេត្តព្រះសីហនុ |
| ៧-លោក | **ឯក សំអឿន** | មន្ត្រីធនធានមនុស្ស សាលាខេត្តព្រះសីហនុ |
| ៨-លោកស្រី | **ខាន់ ហុងលី** | មន្ត្រីធនធានមនុស្ស សាលាខេត្តព្រះសីហនុ |
| ៩-លោកវេជ្ជបណ្ឌិត | **ពិន សេរីវឌ្ឍនៈ** | មន្ត្រីមន្ទីរសុខាភិបាល ខេត្តកោះកុង |
| ១០-អនុសេនីយ៍ទោ | **មន ចាន់ថា** | អត្តលេខ ៥៩៨៧៧ |
| ១១-អនុសេនីយ៍ទោ | **សួន សុធា** | អត្តលេខ ១៩៥៤៧០ |

| | | |
|---|---|---|
| ១២-អនុសេនីយ៍ត្រី | **ទឹម ទេ** | អត្តលេខ ៥៩៨៨០ |
| ១៣-លោក | **ជ័យ គីមលាង** | សប្បុរសជន |
| ១៤-លោក | **អាត់ មូល** | សប្បុរសជន |
| ១៥-លោក | **ហាយតិន** | សប្បុរសជន |
| ១៦-លោក | **ញាំ ទេ៉ន** | សប្បុរសជន |
| ១៧-លោក | **ឡុង គាន** | សប្បុរសជន |
| ១៨-លោក | **មាជ ចាន់** | សប្បុរសជន |
| ១៩-លោក | **យឹម ប្រុង** | គ្រូបង្គោលបង្រៀនផ្នែកកសិករផលិតពូជត្រី ខេត្តសៀមរាប |
| ២០-អនុសេនីយ៍ត្រី | **កែប សៅស៊ី** | អត្តលេខ ៧១០៨៤ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ចំនួន ១៩គ្រឿង ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងសង្គម កន្លងមកដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | |
|---|---|
| ១-ព្រះធិនវំសរក្ខិតោ **ធឹង ច័ន្ទត្រា** | ចៅអធិការវត្តប៉ាផា ខេត្តក្រចេះ |
| ២-លោក **តូច សុគន្ធ** | សប្បុរសជន |
| ៣-លោកស្រី **អ៊ុក រីដា** | ជំនួយការលោកជំទាវ ឃួនសុដារី |
| ៤-លោក **ហេង គឹមសុខ** | សប្បុរសជន |

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា**

| | |
|---|---|
| ១-លោក **អ៊ិត ហ៊ុនលី** | មន្ត្រីនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |
| ២-លោក **កោះ សុគន្ធី** | មន្ត្រីនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |
| ៣-កញ្ញា **ហង្ស ម៉ារីនី** | សប្បុរសជនរាជធានីភ្នំពេញ |
| ៤-លោក **ឡុក ចាន់ថន** | សប្បុរសជនរាជធានីភ្នំពេញ |
| ៥-លោក **ទឿន តុលា** | សប្បុរសជនរាជធានីភ្នំពេញ |
| ៦-លោក **ជួប ប៊ុនធឿន** | សមាជិកក្រុមប្រឹក្សាខណ្ឌជ្រោយចង្វារ |
| ៧-លោក **ជឹម គិរីទ្ធ** | សប្បុរសជនរាជធានីភ្នំពេញ |
| ៨-កញ្ញា **លី សុនសោភា** | សប្បុរសជនរាជធានីភ្នំពេញ |
| ៩-លោកស្រី **រ័ត្ន ស្រីយ៉ា** | សប្បុរសជនរាជធានីភ្នំពេញ |
| ១០-កញ្ញា **ខង្ស ដានី** | សប្បុរសជនរាជធានីភ្នំពេញ |

| | |
|---|---|
| ១១-វរសេនីយ៍ទោ **ឡុង ស៊ីណា** | អត្តលេខ ០១៤៨៣៧ នាយយោធាក្រសួងការពារជាតិ |
| ១២-លោក **ពុម្ព ពន្លឺ** | សប្បុរសជនរាជធានីភ្នំពេញ |
| ១៣-លោកស្រី **ណោច ដាលីស** | សប្បុរសជនរាជធានីភ្នំពេញ |
| ១៤-លោក **អ៊ុំ ចិន្តា** | មន្ត្រីក្រសួងព័ត៌មាន |
| ១៥-លោក **កុល ដាន់ណា** | មន្ត្រីក្រសួងព័ត៌មាន |

**មាត្រា ២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ៣ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ១៣គ្រឿង ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងសង្គម កន្លងមកដូចមានរាយនាមខាងក្រោម៖

**ក-មេដាយ មាសការងារ**

១-ព្រះគ្រូអគ្គប្បញ្ញោ **ម៉ិច សាមីឌី** ព្រះចៅអធិការវត្តភ្នំតាមោគ្គ

២-អ្នកស្រី **ម៉ន ជីណា** សប្បុរសជនរាជធានីភ្នំពេញ

៣-ឧបាសក **អ៊ីវ ស៊ីវឆ្វន** សប្បុរសជនរាជធានីភ្នំពេញ

៤-ឧបាសិកា **អៀ ឡៃឆៀង** សប្បុរសជនរាជធានីភ្នំពេញ

៥-លោកតា **សុត ឌន** សប្បុរសជនភូមិស្រង់

៦-អនុសេនីយ៍ទោ **ជុច សុភា** អត្តលេខ ២១០៨៦ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល

៧-អនុសេនីយ៍ទោ **ហ្វា វ៉ានី** អត្តលេខ ៣៩០០២ នាយនគរបាលក្រសួងមហាផ្ទៃ

**ខ-មេដាយប្រាក់ការងារ**

១-ឧបាសក **ព្រំ អន** សប្បុរសជនភូមិស្រង់

២-ឧបាសក **ឆាន ម៉ន** សប្បុរសជនភូមិស្រង់

៣-ឧបាសក **ហង្ស សេម** សប្បុរសជនភូមិស្រង់

៤-ឧបាសក **សោម សុត** សប្បុរសជនភូមិក្រាំងកន្ទួត

៥-ព្រិន្ទបាលទោ **ផាន់ សុផាន** អត្តលេខ ៥៨៤៩៦ មន្ត្រីនគរបាលយុត្តិធម៌ ស្រុកអង្គស្នួល ខេត្តកណ្តាល

៦-លោក **មឿង យ៉ុន** មេភូមិគោល ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល

**មាត្រា ២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយសនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៨៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជាកិច្ចបញ្ចាមរណៈ ជូនចំពោះសពលោក **ខាំ លក្ខិណា** ប្រធានការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម នៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តកណ្តាល ដែលរយៈពេល ៣៣ឆ្នាំ កន្លងមក លោកបានខិតខំអស់ពីកម្លាំងកាយចិត្ត និងទទួលបានស្នាដៃល្អប្រសើរក្នុងការបម្រើជាតិមាតុភូមិលើវិស័យវប្បធម៌ ហើយបានទទួលមរណភាពដោយរោគាពាធ ។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ** ចំនួន ០៣គ្រឿង ប្រគេន និងជូនព្រះសង្ឃ មន្ត្រីរាជការ ចំនួន ០៣រូប ដែលបានបរិច្ចាគបច្ច័យ ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តបន្ទាយជ័យមង្គល នៅឃុំកំពង់ទ្រាល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ព្រះគ្រូ | **អ៊ឹម លាងហ៊ុន** | ព្រះចៅអធិការវត្តបន្ទាយជ័យមង្គល |
| ២-លោក | **ទ្រី ឧុត្តា** | អភិបាលរងស្រុកក្រូចឆ្មារ |
| ៣-លោក | **ម៉ាន សុះ** | មេឃុំកំពង់ទ្រាស |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ០៣ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពីការជូនមេដាយការងារ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ២៤គ្រឿង ជូនមន្ត្រីរាជការ ចំនួន ២៤រូប ដែលបានបរិច្ចាគបច្ច័យព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តបន្ទាយជ័យមង្គល នៅឃុំកំពង់ទ្រាល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | |
|---|---|
| ១-លោក **ឈន ស៊ីវឡេង** | ក្រុមប្រឹក្សាឃុំ |
| ២-លោក **គោគ ហ៊ិនឡេង** | ក្រុមប្រឹក្សាឃុំ |
| ៣-លោកស្រី **ម៉ាន សិលហះ** | ក្រុមប្រឹក្សាឃុំ |
| ៤-លោក **ស្រេង ឈុន** | គណៈកម្មការវត្តបន្ទាយជ័យមង្គល |
| ៥-លោក **ស៊ឹម រុក្ខា** | ប្រធានគណៈកម្មការវត្តបឹងរម្យ |
| ៦-លោក **អន ជាទី** | គណៈកម្មការវត្តបឹងរម្យ |
| ៧-លោក **ហ៊ីរ គីមសេង** | នាយកសាលាបឋមសិក្សាភូមិទី២ |
| ៨-លោក **ស្រ៊ុន ម៉ាណូ** | នាយកអនុវិទ្យាល័យភូមិទី២ |
| ៩-លោក **ចោង ស៊ាងហៃ** | នាយកសាលាបឋមសិក្សាបឹងរម |
| ១០-លោក **សម សុខមេត** | មេប៉ុស្តិ៍ឃុំកំពង់ទ្រាស |

**ខ-មេដាយប្រាក់ការងារ**

| | |
|---|---|
| ១-លោក **អ៊ុំ ឆែម** | មេភូមិទី១ |
| ២-លោក **ស៊ាង ស៊ុន** | មេភូមិទី២ |
| ៣-លោក **ណូ សុះ** | មេភូមិទី៣ |
| ៤-លោក **កើ លី** | មេភូមិទី៤ |
| ៥-លោក **ទូលស៍ ម៉ាត់** | មេភូមិទី៥ |
| ៦-លោក **ស្រះ ស្រ៊ុ** | អនុភូមិទី៦ |
| ៧-លោក **ឆេង មានិត** | ស្មៀនឃុំ |
| ៨-លោក **ស៊ិន សុខ** | អាចារ្យវត្តបន្ទាយជ័យមង្គល |
| ៩-លោក **អន ថុន** | អាចារ្យវត្តបឹងរម្យ |
| ១០-លោក **អ៊ីត ស្លេះ** | ទូនភូមិទី៥ |
| ១១-លោក **រូន ម៉ាត់** | ទូនភូមិទី៣ |
| ១២-លោក **យ៉េប ស្លេម៉ាន** | កឹម |
| ១៣-លោក **សា ឈោះ** | ទូនភូមិទី៦ |
| ១៤-លោក **ស្រី សុផល** | សកម្មជន |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ :** ប្រគល់ភារកិច្ចជូន កញ្ញា **វង្ស សុបញ្ញា** ឲ្យបំពេញមុខងារជាអនុប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើ អគ្គនាយករង ជំនួសកញ្ញា អ៊ូ ស៊ីរីតា ដែលបានចូលនិវត្តន៍ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសហមេត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ជូនសប្បុរសជនបរទេស ចំនួន ០៤រូប ដែលបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងសកម្ម និងបរិច្ចាគថវិកា ជួយកសាង សមិទ្ធផលនានាលើវិស័យព្រះពុទ្ធសាសនា នៅវត្តវត្តបញ្ចសិលា (ហៅវត្តថ្មគ្រែ) និងជួយឧបត្ថម្ភដល់ជនពិការ កុមារកំព្រា ចាស់ជរាគ្មានទីពឹង ស្ថិតនៅឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- Mr. Pham Trong Nhon | ក្រុមហ៊ុន Vietnam (Kampuchia) Economy trade and Industry Company Limited (VKETI) .co,ltd | បរិច្ចាគថវិកា ៥០.០០០ ដុល្លារ |
| ២-Mr. Huyunh Manh Tuan | ក្រុមហ៊ុន Dau Tieng Cambodia | បរិច្ចាគថវិកា ៥០.០០០ ដុល្លារ |
| ៣-Mr. Ho Sy Dinh | ក្រុមហ៊ុន Dau Tieng Kratie | បរិច្ចាគថវិកា ៥០.០០០ ដុល្លារ |
| ៤-Mrs. Mdm Sng | សប្បុរសជនជនជាតិ (Singapore) | បរិច្ចាគថវិកា ៥០.០០០ ដុល្លារ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មីនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា ១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ចំនួន ០៣គ្រឿង ជូនមន្ត្រីអង្គការ Lien AID Singapore ដែលមានស្នាដៃល្អក្នុងការគៀងគរមូលនិធិពីខាងក្រៅជួយកសាង ស្ថានីយ៍ចម្រោះទឹកហូបសុវត្ថិភាព និងប្រព័ន្ធចម្រោះទឹកបានចំនួន១៥កន្លែង នៅខេត្តព្រះវិហារ ខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | **ឈាន យូផេង** | ប្រធានកម្មវិធី |
| ២-លោកស្រី | **ស៊ីម សុគន្ធា** | ប្រធានកម្មវិធី |
| ៣-លោក | **ឡោ សេងចិត្រ** | មន្ត្រីកម្មវិធីជាន់ខ្ពស់ |

**មាត្រា ២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មីនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើសមាហរណកម្មឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិកម្ពុជា ទៅក្នុងឋានន្តរសក្តិ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងបហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩៩៤អនក្រ.តត ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការធ្វើសមាហរកម្មមន្ត្រីរាជការបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

| ២៩ | លោក | ស្រី ចាន់រតនា | អនុប្រធានការិយាល័យរដ្ឋបាល វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍សហគមន៍នេសាទ |
| ៣០ | លោកស្រី | ចាន់ ធុ | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ រដ្ឋបាលជលផល |
| ៣១ | លោក | ជុន ប៊ុនពៅ | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប រដ្ឋបាលជលផល |
| ៣២ | លោក | នេត ចន្ថា | អនុប្រធានការិយាល័យត្រួតពិនិត្យគុណភាព និងសុវត្ថិភាពជលផល រដ្ឋបាលជលផល |
| ៣៣ | លោក | ម៉ុក ពន្លក | នាយរងខណ្ឌរដ្ឋបាលជលផលក្រចេះ រដ្ឋបាលជលផល |
| ៣៤ | លោក | គីម ដារ៉ាក់ | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ចាម រដ្ឋបាលជលផល |
| ៣៥ | លោក | សម សារពៅ | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ រដ្ឋបាលជលផល |
| ៣៦ | លោក | សាត សីហាក់ | នាយរងផ្នែករដ្ឋបាលជលផលផ្សារឆ្នាំង រដ្ឋបាលជលផល |
| ៣៧ | លោក | ភាំង សុកុមារ | នាយរងសង្កាត់រដ្ឋបាលជលផលបរិបូណ៌ ខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង |
| ៣៨ | លោក | សុក វណ្ណា | អនុប្រធាននាយកដ្ឋានការពារដំណាំឧស្សាហកម្ម អគ្គនាយកដ្ឋានកសិកម្ម |
| ៣៩ | លោក | កុយ រ៉ា | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដី អគ្គនាយកដ្ឋានកសិកម្ម |
| ៤០ | លោក | ឆិត ច័ន្ទកុសល | អនុប្រធានការិយាល័យបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស អគ្គនាយកដ្ឋានកសិកម្ម |
| ៤១ | លោកស្រី | ស្រេង សុក្រូកញ្ញា | អនុប្រធានការិយាល័យបច្ចេកទេសក្រោយប្រមូលផល និងទីផ្សារស្រូវ អគ្គនាយកដ្ឋានកសិកម្ម |
| ៤២ | លោក | យស់ គីមសាន | ប្រធានស្ថានីយពិសោធន៍កសិកម្មគោកត្រប់ អគ្គនាយកដ្ឋានកសិកម្ម |
| ៤៣ | លោក | គង់ ពិសិដ្ឋ | អនុប្រធានការិយាល័យដំណាំបន្លែ អគ្គនាយកដ្ឋានកសិកម្ម |

| | | | |
|---|---|---|---|
| ៤៤ | លោកស្រី | ហេង ពិដោរ | អនុប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ អគ្គនាយកដ្ឋានកសិកម្ម |
| ៤៥ | លោក | ង៉ោ ឆន | មន្ត្រីអគ្គនាយកដ្ឋានកសិកម្ម |
| ៤៦ | លោក | ឡេង សំអាត | មន្ត្រីអគ្គនាយកដ្ឋានកសិកម្ម |
| ៤៧ | លោក | ហាម សៀកឡេង | មន្ត្រីអគ្គនាយកដ្ឋានកសិកម្ម |
| ៤៨ | លោក | ហាន់ វាសា្ន | មន្ត្រីការិយាល័យរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៤៩ | លោក | ហែម ផល្លី | មន្ត្រីការិយាល័យរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥០ | លោក | ច្រាក់ សំណាងសុទ្ធិគុណ | មន្ត្រីការិយាល័យបសុព្យាបាល នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥១ | លោកស្រី | ឆយ សុទ្ធារី | មន្ត្រីការិយាល័យផ្សព្វផ្សាយផលិតកម្មបសុព្យាបាល នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥២ | លោកស្រី | ខិន សុខឡាយ | អនុប្រធានមន្ទីរពិសោធន៍គីមីសាស្ត្រ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល |
| ៥៣ | លោក | ដេង សុវណ្ណឌុធី | មន្ត្រីការិយាល័យផែនការ-គណនេយ្យ នាកកេដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៤ | លោក | កែវ ដារី | នាយរងសង្កាត់រដ្ឋបាលព្រៃឈើមេមុត |
| ៥៥ | លោកស្រី | ម៉ែន សុភារម្យ | អនុប្រធានមន្ទីរកសិកម្មខេត្តមណ្ឌលគិរី |
| ៥៦ | លោក | ហ៊ី ហាប់ | ប្រធានការិយាល័យកសិកម្មស្រុកសង្គមថ្មី នៃមន្ទីរកសិកម្មខេត្តព្រះវិហារ |
| ៥៧ | លោក | ឡឹក រត្ន័ | ប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ |
| ៥៨ | លោក | ឈឿន ពន្លឺ | អនុប្រធានការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម មន្ទីរកសិកម្មខេត្តឧត្តរមានជ័យ |
| ៥៩ | លោក | ស៊ឹម បុរ៉ាមី | អនុប្រធានការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង |
| ៦០ | លោក | អាយ ឈិត | អនុប្រធានការិយាល័យផែនការ-គណនេយ្យ មន្ទីរកសិកម្មខេត្តកោះកុង |
| ៦១ | លោក | អ៊ុស ភល្លា | ប្រធានការិយាល័យកសិកម្មស្រុកបាណន់ មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦២ | លោក | ឆែម ចន្ថា | ប្រធានការិយាល័យកសិកម្មស្រុកសង្កែ មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦៣ | លោក | សុខ ពេញនី | ប្រធានការិយាល័យកសិកម្មស្រុកគាស់ក្រឡ មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦៤ | លោក | ជីវ សុភ័ត្រ្តា | អនុប្រធានការិយាល័យកសិ-ឧស្សាហកម្ម មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦៥ | លោក | ប៉ាង គីមសួគ៌ | មន្ត្រីការិយាល័យផិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦៦ | លោក | ទឿង សៅ | មន្ត្រីការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរកសិកម្មខេត្តបាត់ដំបង |
| ៦៧ | លោក | ស្វង តេង | អនុប្រធានការិយាល័យ មន្ទីរកសិកម្មខេត្តរតនគិរី |
| ៦៨ | លោក | ស៊ូ ផល្លី | ប្រធានការិយាល័កសិកម្មស្រុក មន្ទីរកសិកម្មខេត្តរតនៈគិរី |
| ៦៩ | លោក | ឯក សាវី | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៧០ | លោក | សារិ វុទ្ធី | អនុប្រធានការិយាល័យកសិកម្មស្រុកមង្គលបូរី មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៧១ | លោក | សាន វុន | អនុប្រធានការិយាល័យគ្រឿងយន្ត កសិកម្មមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៧២ | លោក | អ៊ុង បូរី | ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្តសៀមរាប |
| ៧៣ | លោក | អាត ផល្លី | ប្រធានការិយាល័យកសិ.ឧស្សាហកម្ម មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ៧៤ | លោក | ឡុង ឃន | មន្ត្រីការិយាល័យក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ៧៥ | លោក | ហែម ធូក | មន្ត្រីការិយាល័យនីតិកម្មកសិកម្ម មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ៧៦ | លោក | អ៊ុក សុវណ្ណា | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម មន្ទីរកសិកម្មខេត្តកណ្តាល |
| ៧៧ | លោក | ជួន កែវ | អនុប្រធានការិយាល័យកសិ-ឧស្សាហកម្ម មន្ទីរកសិកម្មខេត្តកណ្តាល |
| ៧៨ | លោក | ប៊ុន ហុង | ប្រធានការិយាល័យកសិកម្មស្រុកមុខកំពូល មន្ទីរកសិកម្មខេត្តកណ្តាល |
| ៧៩ | លោក | ម៉ៅ សិទ្ធ | អនុប្រធានការិយាល័យកសិកម្មស្រុកអង្គស្នួល មន្ទីរកសិកម្មខេត្តកណ្តាល |
| ៨០ | លោក | ជាប វន្ថា | អនុប្រធានការិយាល័យកសិកម្មស្រុកកណ្តាលស្ទឹង មន្ទីរកសិកម្មខេត្តកណ្តាល |
| ៨១ | លោក | ភិន វុទ្ធី | បន្ត្រីការិយាល័យរដ្ឋបាលបុគ្គលេិក មន្ទីរកសិកម្មខេត្តកណ្តាល |
| ៨២ | លោក | អ៊ុច វណ្ណនី | មន្ត្រីការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរកសិកម្មខេត្តកណ្តាល |
| ៨៣ | លោក | គ្រី ចាន់នី | មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្តកណ្តាល |

| | | | |
|---|---|---|---|
| ៨៤ | លោក | ព្រុំ សុផាត | ប្រធានការិយាល័យកសិកម្មស្រុកបាភ្នំ មន្ទីរកសិកម្មខេត្តព្រៃវែង |
| ៨៥ | លោក | សំ ស៊ីវឌ្ឍថា | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរកសិកម្មខេត្តព្រៃវែង |
| ៨៦ | លោកស្រី | គីម ណារី | មន្ត្រីការិយាល័យគណនេយ្យ ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋ រដ្ឋបាលព្រៃឈើ |
| ៨៧ | លោក | អ៊ុំ ប៉ូលរតនៈ | អនុប្រធានការិយាល័យកំណត់ដែនព្រៃឈើចុះបញ្ជិកា និងប្រើប្រាស់ដីព្រៃឈើ |
| ៨៨ | លោក | ត្រី ម៉ះផល | អនុប្រធានការិយាល័យការពារសត្វព្រៃ និងជីវចម្រុះ រដ្ឋបាលព្រៃឈើ |
| ៨៩ | លោក | ហុង គីមហ៊ាន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន រដ្ឋបាលព្រៃឈើ |
| ៩០ | លោក | ពិន ឌុច | មន្ត្រី នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំនិងព្រៃឯកជន រដ្ឋបាលព្រៃឈើ |
| ៩១ | លោក | សូ ឆា | អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ រដ្ឋបាលព្រៃឈើ |
| ៩២ | លោក | ហុង តា | នាយរងខណ្ឌរដ្ឋបាលព្រៃឈើរតនគីរី រដ្ឋបាលព្រៃឈើ |
| ៩៣ | លោក | សេង យូ | មន្ត្រី ផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃ រដ្ឋបាលព្រៃឈើ |
| ៩៤ | លោក | ស្រស់ សារិន | នាយរងផ្នែករដ្ឋបាលព្រៃឈើសៀមប៉ាង រដ្ឋបាលព្រៃឈើ |
| ៩៥ | លោក | គង់ ធីរៈ | នាយសង្កាត់រដ្ឋបាលព្រៃឈើសែនមនោរម្យ រដ្ឋបាលព្រៃឈើ |
| ៩៦ | លោក | អ៊ុំ ស៊ីណាង | នាយរងផ្នែករដ្ឋបាលព្រៃឈើព្រែកប្រសព្វ រដ្ឋបាលព្រៃឈើ |
| ៩៧ | លោក | ទឹម សុខុម | នាយសង្កាត់រដ្ឋបាលព្រៃឈើចំការលើ រដ្ឋបាលព្រៃឈើ |
| ៩៨ | លោក | ហេង សុទ្ធិគុណា | មន្ត្រីផ្នែករដ្ឋបាលព្រៃឈើមេមត់ រដ្ឋបាលព្រៃឈើ |
| ៩៩ | លោក | ប៊ុ វណ្ណៈ | នាយផ្នែករដ្ឋបាលព្រៃឈើព្រះនេត្រព្រះ រដ្ឋបាលព្រៃឈើ |
| ១០០ | លោក | នួន សុខុម | នាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ រដ្ឋបាលព្រៃឈើ |
| ១០១ | លោក | ឃាង សំរិត | នាយផ្នែករដ្ឋបាលព្រៃឈើរវៀង រដ្ឋបាលព្រៃឈើ |
| ១០២ | លោក | សុទ្ធ ម៉ារី | នាយផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម រដ្ឋបាលព្រៃឈើ |
| ១០៣ | លោក | ឃិន វណ្ណៈ | នាយរងផ្នែករដ្ឋបាលព្រៃឈើសណ្តាន់ រដ្ឋបាលព្រៃឈើ |
| ១០៤ | លោក | ស៊ិនតូ តុលា | នាយរងផ្នែករដ្ឋបាលព្រៃឈើស្ទោង រដ្ឋបាលព្រៃឈើ |
| ១០៥ | លោក | ហ៊ឹម សំណាង | មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើកណ្តាល រដ្ឋបាលព្រៃឈើ |
| ១០៦ | លោក | ញ៉ៀម តារារិទ្ធ | នាយផ្នែករដ្ឋបាលព្រៃឈើកណ្តាល រដ្ឋបាលព្រៃឈើ |
| ១០៧ | លោក | ហេង សុថារិទ្ធិ | នាយរងសង្កាត់រដ្ឋបាលព្រៃឈើគងពិសី រដ្ឋបាលព្រៃឈើ |
| ១០៨ | លោក | ទ្រឿង និស្ស័យ | នាយរងផ្នែករដ្ឋបាលព្រៃឈើ ក្រវ៉ាញ រដ្ឋបាលព្រៃឈើ |
| ១០៩ | លោក | ឆុច ម៉េងហួរ | មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង រដ្ឋបាលព្រៃឈើ |
| ១១០ | លោក | កង គីមលី | នាយខណ្ឌរដ្ឋបាលព្រៃឈើកំពត រដ្ឋបាលព្រៃឈើ |
| ១១១ | លោក | ពៅ សារឿន | មន្ត្រីផ្នែករដ្ឋបាលព្រៃឈើតាកែវ រដ្ឋបាលព្រៃឈើ |
| ១១២ | លោក | ហ៊ិន ប៊ុច | អនុប្រធានមន្ទីរកសិកម្មរាជធានីភ្នំពេញ |
| ១១៣ | លោក | ឃាង ម៉ារិទ្ធ | អនុប្រធានការិយាល័យផលិតកម្មសត្វ និងបសុព្យាបាលសត្វ មន្ទីរកសិកម្មរាជធានីភ្នំពេញ |
| ១១៤ | លោក | អ៊ុំ រដ្ឋវិបុល | អនុប្រធានការិយាល័យកសិ-ឧស្សាហកម្ម មន្ទីរកសិកម្មរាជធានីភ្នំពេញ |
| ១១៥ | លោកស្រី | អ៊ិន សុខឡូ | អនុប្រធានការិយាល័យក្សេត្រសាស្ត្រ មន្ទីរកសិកម្មរាជធានីភ្នំពេញ |
| ១១៦ | លោក | ម៉ែន សំបូរ | មន្ត្រីការិយាល័យរដ្ឋបាល មន្ទីរកសិកម្មរាជធានីភ្នំពេញ |
| ១១៧ | លោក | ប៊ូ ស៊ីថា | ប្រធានការិយាល័យកសិ-ឧស្សាហកម្ម មន្ទីរកសិកម្មខេត្តស្វាយរៀង |
| ១១៨ | លោក | ឡោ ច័ន្ទកុសល | ប្រធានការិយាល័យគ្រឿងយន្តកសិកម្ម មន្ទីរកសិកម្មខេត្តស្វាយរៀង |
| ១១៩ | លោក | ស៊ាង ផល្លី | អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក នៃមន្ទីរកសិកម្មខេត្តតាកែវ |
| ១២០ | លោកស្រី | ហង់ ណាទី | មន្ត្រីផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តតាកែវ |
| ១២១ | លោក | កេត សារឿន | អនុប្រធានការិយាល័យនីតិកម្មកសិកម្ម មន្ទីរកសិកម្មខេត្តក្រចេះ |
| ១២២ | លោក | ពេជ សំណាង | អនុប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៣ | កញ្ញា | ជោគ ច័ន្ទតំរុក្ខី | អនុប្រធានមជ្ឈមណ្ឌលព័ត៌មានវិទ្យា សាកលវិទ្យាល័យភូមិន្ទកសិកម្ម |

| | | | |
|---|---|---|---|
| ១២៤ | លោក | **សៀង ចាន់សយ** | បុគ្គលិកការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុ សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៥ | លោក | **អ៊ុន ម៉ុនលាង** | គ្រូបង្រៀន មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៦ | លោក | **សេង សុខសាន្ត** | គ្រូបង្រៀន មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៧ | លោក | **អែម ចាន់ថន** | គ្រូបង្រៀនឧត្តមសិក្សា សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៨ | លោកស្រី | **ងុំ ដារ៉ាទី** | មន្ត្រីបម្រើភ្ញៀវ សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១២៩ | លោកស្រី | **អ៊ុន ចន្ទី** | មន្ត្រីបម្រើភ្ញៀវ សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១៣០ | លោក | **អ៊ឹម ទឿន** | អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរកសិកម្មខេត្តកំពង់ចាម |
| ១៣១ | លោក | **សាន សារ៉ាត** | មន្ត្រីការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរកសិកម្មខេត្តកំពង់ចាម |
| ១៣២ | លោក | **ឡា គឹមសាត** | មន្ត្រីការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរកសិកម្មខេត្តកំពង់ចាម |
| ១៣៣ | លោកស្រី | **ខៀវ សុភា** | មន្ត្រីការិយាល័យនីតិកម្មកសិកម្ម មន្ទីរកសិកម្មខេត្តកំពង់ចាម |
| ១៣៤ | លោក | **លាង ទុន្នី** | អនុប្រធានការិយាល័យកសិកម្មស្រុកព្រៃឈរ មន្ទីរកសិកម្មខេត្តកំពង់ចាម |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៥ ស.ជណស

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦**

**១. សេចក្តីផ្តើម**

មាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ដំណាក់កាលគឺ (១)- **ដំណាក់កាលទី១:** ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនាដល់ខែឧសភា (២)- **ដំណាក់កាលទី២:** ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង (៣)- **ដំណាក់កាលទី៣:** ការអនុម័តថវិកា ពីខែតុលា ដល់ ខែធ្នូ។ សម្រាប់ដំណាក់កាលទី១នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដើម្បីឱ្យក្រសួង ស្ថាប័ននីមួយៗមានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធ-សាស្ត្រថវិកាឆ្នាំ២០១៦ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ២០១៦។ ហេតុនេះសម្រាប់ជំហានបន្ទាប់នៃដំណាក់-កាលទី១ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦នេះ ដើម្បីផ្តល់គោលការណ៍ណែនាំ និងមគ្គុទ្ទេសក៍បច្ចេកទេសសំខាន់ៗសម្រាប់ជាជំនួយដល់គ្រប់ក្រសួង ស្ថាប័នក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផែនការថវិការយៈពេលមធ្យមបីឆ្នាំរំកិលដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំក្នុងដំណាក់កាលដំបូងនៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយឡែកមួយទៀតស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

ផែនការយុទ្ធសាស្ត្រថវិកាក៏ជាឧបករណ៍ដ៏សំខាន់មួយសម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោ-បាយ (២)-បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣)-ជាមូលដ្ឋានសម្រាប់ពន្យល់និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤)-ធានានិរន្តរភាពនៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានដាក់ចេញ និង (៥)-ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ថវិកា និងការវិភាជថវិកាប្រចាំឆ្នាំ។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ ភាពច្បាស់លាស់នៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាព សូចនាករ និង គោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តថវិកា

ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ក្នុងន័យនេះ ក្រសួង ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិកាតែមួយ ដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទក្រសួង ស្ថាប័ននោះ។

ទន្ទឹមនឹងនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាមិនអាចខ្វះបានឡើយដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពនិងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការវិភាជនិងគ្រប់គ្រងថវិកា។ ក្នុងន័យនេះ *ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវរៀបចំក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពី នាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ **និងអង្គភាពគ្រប់គ្រងគម្រោង*** មានដំណើរការដោយសកម្មប្រកបដោយការទទួលខុសត្រូវ។ **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យធនធានទាំងអស់ ក៏ដូចជាសកម្មភាពការងារទាំងអស់របស់ក្រសួង ស្ថាប័នខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាឱ្យការវិភាជថវិកាមានប្រសិទ្ធភាព (ចំសេចក្តីត្រូវការពិតប្រាកដ) និងមានតុល្យភាពក្នុងការវិភាជថវិកាទៅតាមនិងរវាងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី/យុទ្ធសាស្ត្រអាទិភាព នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នដែលបានរៀបចំ។

ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០០៨ មកទល់នឹងពេលនេះការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជារួមត្រូវបានកែលម្អជាលំដាប់។ ទោះជាយ៉ាងនេះក្តី ការងារនេះនៅតែមិនទាន់បានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយទេ ជាពិសេសក្រសួង ស្ថាប័នចាំបាច់ត្រូវកែលម្អថែមទៀតនូវផែនការយុទ្ធសាស្ត្រថវិកាស្របទៅតាមស្មារតី និងលទ្ធផលនៃការរៀបចំថវិកាឆ្នាំ២០១៥កន្លងទៅ។ លើសពីនេះនៅពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងស្ថិតក្នុងដំណាក់កាលទី២ថ្មីនៃការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការត្រៀមចូលដំណាក់កាលទី៣គឺការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោ-បាយ និងស្របតាម "ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០" ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាថ្មីគឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវបានបង្កើនពីចំនួន១០ នៅឆ្នាំ២០១៥ ដល់ចំនួន២៥ នៅឆ្នាំ២០១៦ រួមមាន÷

- ក្រសួងចំនួន១០ អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ក្នុងឆ្នាំ២០១៥រួមមាន÷ ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិង សំណង់, និងក្រសួងយុត្តិធម៌។
- ក្រសួង ស្ថាប័នថ្មីចំនួន ១៥ និងមន្ទីរជំនាញរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៦ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកា-

កម្មវិធីនៅឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ រួមមាន÷ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា, និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកា និងលើការអនុវត្តថវិកា នឹងត្រូវផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្រសួងសាមី ចំណែកឯសិទ្ធិនៃការទទួលខុសត្រូវក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ទៅអង្គភាពថវិការបស់ក្រសួង ស្ថាប័ន។ ក្នុងន័យនេះ ក្រសួង ស្ថាប័នទាំងនេះកាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ក្នុងបរិការណ៍នេះ ដើម្បីជួយឱ្យក្រសួង ស្ថាប័នក្នុងការយកចិត្តទុកដាក់លើកកម្ពស់គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ឱ្យបានប្រសើរថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ដូចតទៅ÷

## ២. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានតួនាទីផ្តល់ជាទស្សនវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះបង្កើតបានជាលំហថវិការួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចកំណត់ទិសដៅការងាររយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។ នៅក្នុងន័យនេះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷

### ២.១. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្អែកលើនិន្នាការសេដ្ឋកិច្ចឆ្នាំកន្លងទៅ ស្ថានភាពល្អប្រសើរនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល និងសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើកដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៥ ត្រូវបានព្យាករថាអាចសម្រេចបានក្នុងរង្វង់៧% ដូចតាមការគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ ចំពោះកំណើនសេដ្ឋកិច្ច

សម្រាប់ឆ្នាំ២០១៦វិញ តាមការព្យាករអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៣% វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ៩,៦% ដែលក្នុងនោះវិស័យវាយនភណ្ឌនឹងអាចសម្រេចបានប្រមាណ៨,៤% និងវិស័យសេវាកម្មគ្រោងថាអាចនឹងសម្រេចបានកំណើនប្រមាណតែ៦,៥% ប៉ុណ្ណោះ។

អតិផរណានៅឆ្នាំ២០១៥ តាមការព្យាករនឹងរក្សាបានក្នុងកម្រិត៣,៥%គឺដូចទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ហើយនឹងបន្តរក្សាកម្រិតថេរក្នុងរង្វង់៣,៥% ដដែលក្នុងឆ្នាំ២០១៦។ អត្រាប្តូរប្រាក់នៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានតម្លៃជាមធ្យម៤ ០៥០រៀល ក្នុង១ដុល្លារអាមេរិក ដូចគ្នានឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ តាមការព្យាករនៅឆ្នាំ២០១៦ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤០៥០រៀលក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

ឱនភាពគណនីចរន្តនៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានកម្រិត១០,៣%នៃផ.ស.ស គឺបានប្រសើរឡើងធៀបនឹងឆ្នាំ២០១៤ ដែលមានកម្រិត១១,២%នៃផ.ស.ស។ ទន្ទឹមនេះ តាមការព្យាករនៅឆ្នាំ២០១៦ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះទៀតមកត្រឹម៩,៧%នៃផ.ស.ស។ និន្នាការនៃការធ្លាក់ចុះឱនភាពគណនីចរន្ត ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលនិងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៥ ទុនបម្រុងនឹងមានទំហំ៥ ១៤៤លានដុល្លារអាមេរិក និងអាចកើនឡើងលើសពី៥ ៧៣៩លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដែលធានាបានប្រមាណជាង៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

## ២.២ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ដោយផ្អែកលើមូលដ្ឋាននៃ "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**" គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៦-២០១៨ ត្រូវបានកំណត់គោលដៅសំខាន់ៗដូចតទៅ÷

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌និងប្រសិទ្ធភាពដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង បែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀលនៅឆ្នាំ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និង ការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិ

កំណែទម្រង់រដ្ឋបាលសារណៈ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមាន ការកែទម្រង់ប្រព័ន្ធកងកម្លាំងប្រដាប់អាវុធ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល
- បន្តជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
- បង្កើនប្រសិទ្ធភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ
- ធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព
- បន្តការជំរុញការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសបន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព ពង្រីកការទទួលបាន ភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានាបន្តការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោមនេះ÷

- ធានាកំណើនចំណូលចរន្តប្រចាំឆ្នាំបន្ថែម០,៥ពិន្ទុភាគរយនៃផ.ស.ស ដើម្បីឈានទៅសម្រេចឱ្យបាន១៧,៣៥% នៃផ.ស.ស នៅ២០១៦ ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៦,៤២% នៃផ.ស.ស និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិ គឺ០,៩៣% នៃផ.ស.ស។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន៨,៤២%នៃផ.ស.ស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន៦,៥៩% នៃផ.ស.ស និង ចំណូលមិនមែនសារពើពន្ធនិងចំណូលពន្ធផ្សេងទៀត ត្រូវគ្រោងសម្រេចឱ្យបាន២,៣៥% នៃ

ផ.ស.ស។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវគ្រោងសម្រេចឱ្យបានស្មើនឹង ១៧,៥១% នៃផ.ស.ស។

○ ចំណាយសរុបនៅឆ្នាំ ២០១៦ នឹងកំណត់ក្នុងរង្វង់ ២១,២៨% នៃផ.ស.ស ក្នុងនោះចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិគ្រោង២០,៣៤% នៃផ.ស.ស និង ចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រោង ១,៥៦%នៃផ.ស.ស (ឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៦៣% នៃផ.ស.ស)។ ចំណាយចរន្តសរុបត្រូវគ្រោងក្នុងកម្រិត១៣,២៨%នៃផ.ស.ស ដែលចំណាយបន្ទុកបុគ្គលិកគ្រោងប្រមាណ៤៨,៤៨%នៃចំណាយចរន្តសរុប (ពោលគឺមិនឱ្យលើស ៥០%) ឬស្មើប្រមាណ៦,៤៤% នៃផ.ស.ស ដោយផ្តោតអាទិភាពលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ ទន្ទឹមនឹងការគិតគូរផងដែរចំពោះចំណាយមិនមែនបៀវត្សមួយចំនួន ពិសេសតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា ព្រមទាំងតម្រូវការចំណាយក្នុងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះដែរ ចំណាយមូលធនគ្រោងប្រមាណជា៨,០% នៃផ.ស.ស សម្រាប់ឆ្នាំ២០១៦។

○ ក្នុងគម្រោងក្របខណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៦ ត្រូវស្មើនឹង៤,០៧%នៃផ.ស.ស ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយត្រឹម ៣,៧៧%នៃផ.ស.ស។ ទំហំតុល្យភាពខាងលើគឺអាចធានាបាននូវចីរភាពថវិកា ដែលជាគន្លឹះរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើន ជាពិសេសបង្កើននូវលំហថវិកា។ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤-២០១៨ មានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ការគ្រោងថវិកាឆ្នាំ២០១៦ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខណ្ឌនៃវិធានការ ដូចខាងក្រោម÷

**ផ្នែកចំណូល**

ជារួម ក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលទៅតាមគោលដៅកំណត់ខាងលើ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធនិងអាករបន្ថែមដល់ប្រជាជន និងធុរជននោះទេ ពោលគឺរាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយទាំងសម្រាប់រយៈពេលខ្លី និងមធ្យម ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើគេចពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ក្នុងនោះ រួមមានទាំងការកែសម្រួល និងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធ ពិសេសតាមរយៈការជំរុញអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។**

**ក. ផ្នែកចំណូលគយ និងរដ្ឋាករ**

- បន្តពង្រឹងវិធានបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគយគ្រប់រូបភាព
- បន្តពង្រឹងការប្រកាសគយ តាមរយៈការពង្រឹងការគ្រប់គ្រងឯកសារនាំចេញ-នាំចូល និងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ពិសេសចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន

- ពង្រឹងការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ
- ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ
- សិក្សា និង វាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយលើទំនិញនាំចេញ- នាំចូល ក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការដើម្បីធ្វើឱ្យប្រសើរឡើងនូវការកំណត់ពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល
- ជំរុញការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដាឱ្យអស់សក្តានុពល ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរជាតិតែមួយឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន
- បន្តពង្រឹងយន្តការសហប្រតិបត្តិការរវាងគយនិងវិស័យឯកជន
- វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយ ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជ-កម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប
- រៀបចំផែនការអភិវឌ្ឍស្ថាប័ន កែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមារយាទមន្ត្រីគយ។

**ខ. ផ្នែកចំណូលពន្ធដារ**

- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូល
- បន្តពង្រឹង និងកែលម្អការផ្តល់សេវាដល់អ្នកជាប់ពន្ធ
- បន្តកែលម្អការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតការយកចិត្តទុកដាក់លើ÷
  - (១)- ការរៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ
  - (២)- អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ខែជាប់គ្នា
  - (៣)- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមាបន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើងនូវការធ្វើសវនកម្មពន្ធដារ ទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដោយផ្តោតលើ÷
  - (១)- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិ-ភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដារ

រួមដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម

(២)- រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យ មុនពេលចុះសវនកម្មកន្លងមកសម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ

(៣)- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់និងបន្ថយបន្ទុកសវនកម្ម

(៤)- រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមានៈ ធនាគារ សំណង់ ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម។

- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- ជំរុញការបង្កើនចំណូលពីអាករលើតម្លៃបន្ថែម តាមរយៈ÷

(១)- រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត

(២)- បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យដែលមិនមានចែង
ក្នុងច្បាប់ស្តីពីសារពើពន្ធ។

- ពង្រឹងការគ្រប់គ្រងរបបម៉ៅការ និងជំរុញការអនុវត្តរបបស្វ័យប្រកាស តាមរយៈ÷

(១)- រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំរួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែងដែលមានចំណូលខ្ពស់

(២)- រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំព្រួញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។

- ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- បន្តពង្រឹងកម្មវិធីផ្សព្វផ្សាយ និងការអប់រំពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ
- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស

- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីពន្ធដារ។

**គ.ផ្នែកចំណូលមិនមែនសារពើពន្ធ**

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយធ្វើសវនកម្មក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលប្រភេទនេះ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បន្តតាមដានការប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានវិធានការលើកទឹកចិត្ត សមស្របសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀត
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ រួចបង្កើតយន្តការតឹងទារបំណុលទាំងនោះ ដោយចាត់វិធានការព្រមាន ដកហូតអាជ្ញាបណ្ណ លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀត តាមការអនុញ្ញាតរបស់ច្បាប់ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល
- ពង្រឹងការគ្រប់គ្រងកាស៊ីណូ និងចំណូលពីកាស៊ីណូ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ
- ពង្រឹងការគ្រប់គ្រងធនធានប្រេងកាត និងរ៉ែ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ទន្ទឹមនឹងការសិក្សានិងធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ ការបន្តរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យានិងអាជ្ញាបណ្ណដែលបានផ្តល់រួច
- រៀបចំ និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាពនូវការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងការប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា ការលក់សំបុត្រទស្សនាប្រាសាទ រមណីយដ្ឋាន និងទីតាំងប្រវត្តិសាស្ត្រផ្សេងៗ
- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ និងច្បាស់លាស់

- ពង្រឹងការបង់ចំណូលថវិកាពីថ្លៃសម្បទានដីសេដ្ឋកិច្ច និង ផលអនុផលព្រៃឈើពីព្រៃឈើពីសម្បទានិក តាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងការលក់និងការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច នីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច ការបង្កើនយន្តការនិងនីតិវិធីក្នុងការគ្រប់គ្រងនិងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើដីសម្បទានសេដ្ឋកិច្ច វារីអគ្គិសនី ទំនប់ អាងស្រោចស្រព និងពីប្រភពផ្សេងៗទៀត
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើចំណាត់ថ្នាក់សណ្ឋាគារ និងការបង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ
- បន្តពង្រឹងការគ្រប់គ្រង និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈទាំងអស់ តាមរយៈត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ ធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ និងការធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុ ព្រមទាំង ពង្រឹងការអនុវត្តនូវកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ
- ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការសិក្សា និងរៀបចំឡើងវិញនូវក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការកែលម្អលក្ខន្តិកៈគតិយុត្តឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងដើម្បីផ្តល់លទ្ធភាពដល់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថាន ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍស្ថាប័នរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានស្រាប់
- លើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍ និង ជំរុញការរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍
- ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សាអំពីភាពប្រកួតប្រជែងរបស់កម្ពុជាពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗ នៅក្នុងតម្លៃនៃការធ្វើធុរកិច្ច អាជីវកម្ម និងពាណិជ្ជកម្មជារួមដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវា និងរង្វាន់លើកទឹកចិត្ត ផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ
- ពិនិត្យឡើងវិញ និងធ្វើកែប្រែជាយថាហេតុលើកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល

- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ និងការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

**ផ្នែកចំណាយ**

- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌ សង្គតិភាព ការធានាបាននិរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល
- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ពិសេសការពង្រឹងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាពីចំនួន១០ ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០១៥ ឱ្យឡើងដល់ ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេល ក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ទាំងចំណាយបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិក) ទាំងចំណាយមូលធន
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដោយបង្កើនការយកចិត្តទុកដាក់លើមុខចំណាយដែលបង្កើនផលិតភាព និងទ្រទ្រង់កំណើន
- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ចំណាយថវិកាលើមុខចំណាយទំនិញ និងសេវាមួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍និងអ៊ិនធើណែត ការកាត់បន្ថយនូវបេសកកម្មទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិតហើយមានតម្លៃខ្ពស់
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លីនិងអភិវឌ្ឍន៍ជនបទ ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យ។ល។
- បន្តការវិនិយោគលើការពង្រីក ការកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី ។ល។
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញផលិតឧស្សាហកម្មនិងកសិផលការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីគាំទ្រដល់ការជំរុញផលិតកម្មម្ហូបអាហារ
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយក្នុងគោលបំណងរក្សាឱនភាពថវិកាឱ្យនៅត្រឹមកម្រិតសមរម្យមួយដែលមិនប៉ះពាល់និរន្តរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន **"លំហថវិកា"** សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការ

ចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់នានាទៀត
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ
- ពង្រឹងការគ្រប់គ្រង ឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត ក្នុងគោលបំណងផ្ទៀងផ្ទាត់ធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីថ្មី។

### ៣. រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិកា

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានគូសវិលេចខាងលើបានកំណត់អំពីគោលដៅរួមនៃការប្រមូលចំណូល និងវិធានការចាំបាច់នានាដែលត្រូវអនុវត្តដើម្បីសម្រេចឱ្យបាននូវគោលដៅដែលបានដាក់ចេញនោះ ចំណែកខាងផ្នែកចំណាយវិញបានកំណត់អំពីគោលដៅរួមនៃចំណាយ និងបណ្តាអាទិភាពចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ២០១៤-២០១៨។ ដូចនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ ដើម្បីឈានទៅរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឱ្យបានល្អត្រឹមត្រូវ និងមានភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យក្រសួង ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នា រចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកា ត្រូវរៀបចំទៅតាមទម្រង់ដូចខាងក្រោម ÷

**-ផ្នែកទី១:** សេចក្តីផ្តើមៈ

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ត្រូវចាប់ផ្តើមដោយការរៀបរាប់អំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ និងការព្យាករសភាពការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងបញ្ហាប្រឈមផ្សេងៗ ដែលត្រូវដោះស្រាយជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០១៥ និងឆ្នាំខាងមុខ ។ បន្ទាប់មកត្រូវមានការរៀបរាប់អំពីវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តគោលនយោបាយដែលបាន

ដាក់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី១នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

**-ផ្នែកទី២:** គោលបំណងគោលនយោបាយៈ

គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេល មធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុ នៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនអាចត្រួតពិនិត្យនិងវាយតម្លៃឡើងវិញនូវ គោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥របស់ខ្លួនបាន ដើម្បីកែ សម្រួលគោលបំណងគោលនយោបាយឱ្យកាន់តែច្បាស់លាស់ និងសមស្របតាមវឌ្ឍនភាពជាក់ស្តែងនៃវិស័យ រៀងៗខ្លួន។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី២នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

**-ផ្នែកទី៣:** កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពៈ

ការរៀបចំកម្មវិធី (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ត្រូវឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ហើយត្រូវបញ្ជាក់អំពី គោលបំណងនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែល បានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតឈ្មោះកម្មវិធី រៀបរាប់និងពន្យល់អំពី គោលបំណងនៃកម្មវិធីដែលបានបង្កើត ឬ យុទ្ធសាស្ត្រអាទិភាព ព្រោះកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព គឺជា ឧបករណ៍ដែលបានបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋានក្រោមឱវាទរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង ស្ថាប័នសាមី ដាក់ចេញនូវ អនុកម្មវិធី និង ចង្កោមសកម្មភាព (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬ ចង្កោមសកម្មភាពអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ព្រមទាំងលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រ អាទិភាពទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២។

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ត្រូវមានខ្លឹមសារទូលាយ និងគ្របដណ្តប់បានទាំងស្រុងគ្រប់តួនាទី ភារកិច្ច និងបេសកកម្មរបស់ក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មដោយត្រូវគ្របដណ្តប់ លើគម្រោង ឬ សកម្មភាពការងារទាំងអស់ទាំងវាងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នត្រូវ កំណត់អង្គភាពទទួលខុសត្រូវ និងអ្នកគ្រប់គ្រងទៅតាមរចនាសម្ព័ន្ធកម្មវិធី (ចំពោះក្រសួង ស្ថាប័នអនុវត្តថវិកា កម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (ចំពោះក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី)។ ទន្ទឹមនឹងនេះ ក្នុងក្របខណ្ឌនៃ ការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង ស្ថាប័ននីមួយៗត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខណ្ឌទទួល ខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្តឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន។ មន្ទីរជំនាញរាជធានី ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធី ឬយុទ្ធសាស្ត្រ អាទិភាពដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី ខេត្ត គឺជាដៃរបស់ក្រសួងនៅតាមរាជធានី ខេត្ត ដែលមាន ភារកិច្ចរួមចំណែកអនុវត្តបណ្តាកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវណែនាំដល់មន្ទីរជំនាញរបស់ខ្លួននៅរាជធានី ខេត្ត **អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី ខេត្តរបស់ខ្លួនដឹងច្បាស់លាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់។** ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពតែមួយគត់ក្រោមអនុកម្មវិធីរួមមួយនៃកម្មវិធីមួយ លើកលែងតែក្រសួង ស្ថាប័នដែលមានតួនាទីនិងភារកិច្ចច្រើន ហើយការងារនោះភាគច្រើនអនុវត្តនៅថ្នាក់ក្រោមជាតិ ដូចជាក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាលជាដើម ដែលត្រូវមានអនុកម្មវិធីរួមលើសពីមួយ ដែលជាសេវា ឬការងារគាំទ្រដល់កម្មវិធីលើសពីមួយ។ សូមបញ្ជាក់ផងដែរថា ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពមិនឱ្យលើសពី៥ឡើយ ប៉ុន្តែអាចមានអនុកម្មវិធីសមស្រប និងតាមការចាំបាច់។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងផងដែរទាំងធនធានថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនៃផ្នែកទី៣នេះ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី៣នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៤:** សូចនាករ និងគោលដៅសូចនាករៈ

គោលបំណងគោលនយោបាយ និងកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់ និង ត្រូវកំណត់គោលដៅសូចនាករដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករ ឬហៅថាការជ្រើសរើសសូចនាករសម្រាប់ការវាស់វែង ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលក្នុងឆ្នាំគឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/ សមិទ្ធកម្មនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ទៅតាមគោលដៅដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់សមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលសម្រេចបានដោយការបូកបញ្ចូលគ្នានូវលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ក្រសួង ស្ថាប័ននីមួយៗ អាចកែសម្រួលសូចនាករនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ២០១៤ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ២០១៥ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។ **កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករយ៉ាងច្រើនចំនួន៣** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។ បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗនៅក្នុងរយៈពេលមធ្យមនិងវែង(លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុតគឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះចាំបាច់ត្រូវតែមានភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៤នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

**-ផ្នែកទី៥:** ការកំណត់ធនធានៈ

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំង ថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៥នេះទៅ**តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ ការកំណត់អំពីតម្រូវការធនធានដើម្បីអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំណត់ ជាពិសេសកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈកាលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្តែង និងមានសុក្រឹតភាពដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។

ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ដោយផ្អែកលើក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលចំណូលគ្រប់ប្រភេទទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនេះតាម**តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ប៉ុន្តែចំពោះ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្ត្រ រួមមានទាំងគោលនយោបាយ និងវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។ នៅក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវផ្តែកជាសំខាន់លើ÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត។

**-ផ្នែកទី៦:** សេចក្តីសន្និដ្ឋានៈ

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និងការលើកទិសដៅ និងវិធានការដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និងមានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ និងដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ គឺជាដំណាក់កាលទី១នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង ស្ថាប័ននីមួយៗ មានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ដោយផ្សារភ្ជាប់គោលនយោបាយរបស់ក្រសួង ស្ថាប័ន ទៅនឹងថវិកា ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលបានដាក់ចេញរួចហើយ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផ្នែកមួយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការដ៏មានសារៈសំខាន់បំផុតសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ឱ្យបានសមស្រប ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវត្រួតពិនិត្យឡើងវិញនិងវាយតម្លៃលើការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥របស់ខ្លួន និងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ ហើយរៀបចំកែសម្រួលទៅ**តាមទម្រង់គំរូដូចបានភ្ជាប់ជាមួយសារាចរណែនាំនេះ**។

***គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៦ ដែលមានវិសាលភាពគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥*** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលា

គ្រប់គ្រាន់សម្រាប់ពិនិត្យ ឬកសុប និងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិគ្រោះនិងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួង ស្ថាប័នដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើប្រកបដោយគុណភាពទេ ត្រូវបានអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើការវិភាជកញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់និសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសត្រូវទាក់ទងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  "ដើម្បីជូនជ្រាប"
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible]

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែ សម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
  បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៤ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១២១៧/១១ ក.អ.ក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វឺស ហ្គាវ័ន្ត អីភែរីល (ខេមបូឌា) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វឺស ហ្គាវ័ន្ត អីភែរីល (ខេមបូឌា) (FIRST GAWON APPAREL (CAMBODIA) Co., Ltd.) តំណាងដោយ លោក LEE YEON WOO សញ្ជាតិកូរ៉េ អាយុ៥២ឆ្នាំ កាន់លិខិតឆ្លងដែនលេខM61448222 ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 233-23, Dongdaemun-Gu, Seoul, Korea. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ្វឺស ហ្គាវ៉ែន្ត អឺកែវីល (ខេមបូឌា)"*
**ទីតាំងរោងចក្រ៖** *"អាគារលេខ១៧៧១ ផ្លូវជាតិលេខ២ ភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទបញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទបញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្របានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ផលិតកម្មប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សម្គាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទបញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ខែមេសា ឆ្នាំ២០១៥

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៣៧៣.១១.ឧស្ស.ក្រុមព.០៤

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៤២១៩/១៤ គ.វ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្សុងយី ផៅវ័រ អេឃ្វីបមិន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្សុងយី ផៅវ័រ អេឃ្វីបមិន (ZHONGYI POWER EQUIPMENT CO., LTD.) តំណាងដោយ លោក KOU KIN MAN សញ្ជាតិចិន អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M0216289 ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ AVN AMIZADE TAI FONG PLAZA HIL FUNG KOK 13-AND-S MACAU. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| បរិក្ខារអគ្គិសនី | ២៧១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតសម្ភារៈបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច ហ្សុងយី ផៅវ៉េ អេឃ្វីបម៉ិន"*

**ទីតាំងរោងចក្រ៖** *"ផ្លូវជាតិលេខ២១បេ ភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទបញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទបញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្របានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្ររនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ផលិតកម្មប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សម្គាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទបញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ [illegible] ឆ្នាំ២០១៥

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៨ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៤៥១ ឧសក.អឧក.រោងចក្រ.២០១៤

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រផលិតគ្រឿងសង្ហារឹម (ការិយាល័យ ផ្ទះ និងសម្ភារៈផ្សេងៗ) របស់ក្រុមហ៊ុន ស៊ីង បាយអូថេក (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីង បាយអូថេក (ខេមបូឌា) ខូ អិលធីឌី (THINK BIOTECH (CAMBODIA) CO., LTD.) តំណាងដោយ លោក KIM HWANGCHEUL បង្កើតរោងចក្រផលិតគ្រឿងសង្ហារឹម (ការិយាល័យ ផ្ទះ និងសម្ភារៈផ្សេងៗ) ដែលមានទីតាំងស្ថិតនៅ ភូមិអាចេន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-គ្រឿងសង្ហារឹមសម្រាប់ការិយាល័យ (ពីឈើ) | ៣១០០ |
| ២-គ្រឿងសង្ហារឹមសម្រាប់ផ្ទះ (ពីឈើ) | ៣១០០ |
| ៣-សម្ភារៈផ្សេងៗ (ពីឈើ) | ៣១០០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពី ការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** "រោងចក្រផលិតគ្រឿងសង្ហារឹម (ការិយាល័យ ផ្ទះ និងសម្ភារៈផ្សេងៗ) ស៊ីង បាយអូវថេក (ខេមបូឌា) ខូ អិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហរ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន. ស្របតាមមាត្រា១៦ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្មនៅសប្តាហ៍ទីមួយ នៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាព ឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ក្នុងករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់របាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបានអនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី·វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តក្រចេះ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០២៣៣ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១៣ **ខែ** មករា **ឆ្នាំ** ២០១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ Co.៣៨០១KH/២០១៤ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុន ដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | នាមករណ៍របស់ក្រុមហ៊ុន | : | **សេត អាត អាឃីធេក ខូ អិលធីឌី**<br>**SET ART ARCHITECT Co., Ltd.** |
| | មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ២- | អភិបាលក្រុមហ៊ុន | : | លោក **ព្រំ ពិសុទ្ធ** ប្រធានក្រុមប្រឹក្សាភិបាល<br>លោកស្រី **ហែម គីមអេង** អភិបាល |
| ៣- | ដើមទុនក្រុមហ៊ុន | : | ២០.០០០.០០០ រៀល |
| ៤- | ទីស្នាក់ការក្រុមហ៊ុន | : | លេខ ២៥៣ ផ្លូវលេខ ៥៩០ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ |
| ៥- | កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ ទំនិញគ្រប់ប្រភេទ<br>-នាំចូលឱសថ សម្ភារៈបរិក្ខាពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ<br>-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសម្បែង<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្នែកព័ត៌មានវិទ្យា<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន |

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

អ៊ឹក-ប្រូជា

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព.សរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៣០៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ជំរាបមក**

លោក **គុជ ប៊ុនរ៉ាល** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ប៊ីឌីខេធេល ខូ អិលធីឌី**
អាសយដ្ឋាន: លេខ ៥៦ ផ្លូវលេខ ៣៣៧ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កម្មវត្ថុ**: ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ប៊ីឌីខេធេល ខូ អិលធីឌី** BDKtel Co., Ltd.

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៤ - ១២ - ២០១៤
-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសំរេចសម្ធហភាព ចុះថ្ងៃទី ២២ - ១២ - ២០១៤
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី ២២ - ១២ - ២០១៤
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិបត្រពាណិជ្ជកម្មលេខ ៥២៣ ចេញផ្សាយថ្ងៃទី ១៥ - ០១ - ២០១៥

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា: ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ប៊ីឌីខេធេល ខូ អិលធីឌី** BDKtel Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co.២២៦៨ KH/២០១០ ចុះថ្ងៃទី ១១-១១-២០១០ ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើនិងយោងខាងលើគឺ:

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០១រូប គឺលោក ទី គឹមគី "អភិបាលចាស់"
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកហ៊ុន និងការកាន់កាប់ភាគហ៊ុនថ្មី:

- លោក **គុជ ប៊ុនរ៉ាល** (សញ្ជាតិ: ខ្មែរ)
  កាន់កាប់ភាគហ៊ុនចំនួន ៦៥០ ភាគហ៊ុន
- លោក **ឌួង ដារិទ្ធ** (សញ្ជាតិ: ខ្មែរ)
  កាន់កាប់ភាគហ៊ុនចំនួន ៣៥០ ភាគហ៊ុន

-ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី:

- លោក **គុជ ប៊ុនរ៉ាល** ប្រធានក្រុមប្រឹក្សាភិបាល
- លោក **ឌួង ដារិទ្ធ** អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់  ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុននេះ។

អាស្រ័យហេតុនេះ  សូមលោកជ្រាប  និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ



ឃុយ_សុជាតិ

**<u>ចម្លងជូន:</u>**

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងទេសចរណ៍
-ក្រសួងពត៌មាន
-ក្រសួងបរិស្ថាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-អគ្គនាយកដ្ឋានពន្ធដារ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
-ឯកសារ -កាលប្បវត្តិ
ទ.ស.រ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០៣០៧ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១៣ **ខែ** មករា **ឆ្នាំ ២០**១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ជំរាបមក**

លោក JOHN BRINSDEN ប្រធានក្រុមប្រឹក្សាភិបាលនៃ **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
អាសយដ្ឋាន : អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុ</u>** : ករណីសុំបង្កើតសាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ACLEDA Bank Plc.

**<u>យោង</u>** : -សំណើរបស់ធនាគារលេខ ធអក ៣៧៤៥/១៤ ចុះថ្ងៃទី ១៥-១២-២០១៤
-សេចក្តីសំរេចរបស់ធនាគារលេខ ធអក ១៤២៩/១៤ ចុះថ្ងៃទី ២៩-០៥-២០១៤
-អាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារលេខ ធ ០៦-១៨/០២/១៤/០១ ចុះថ្ងៃទី ១៨-០៣-២០១៤ របស់ធនាគារជាតិនៃកម្ពុជា

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការបង្កើតសាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ACLEDA Bank Plc. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. ៥១៨៥KH/២០០០ ចុះថ្ងៃទី ០៥-០៦-២០០០ មួយកន្លែង :

១-នាមករណ៍របស់សាខា : **ធនាគារ អេស៊ីលីដា ភីអិលស៊ី " សាខាស្រុកព្រៃនប់ - ឃុំវាលរេញ "**
ACLEDA Bank Plc." Prey Nob District Branch – Veal Renh Commune "

២-នាយកសាខា : លោក **សំ បញ្ញាពិសិដ្ឋ** " តតិយជន "

៣-ទីស្នាក់ការសាខា : ផ្លូវជាតិលេខ ៤ ក្រុមទី១០ ភូមិបឹងវែង ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

៤-កម្មវត្ថុអាជីវកម្ម : -ប្រតិបត្តិការធនាគារ ។

ធនាគារត្រូវសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុរដ្ឋលេខាធិការ**

**ឃុយ_សុជានី**

**<u>ចម្លងជូន</u>** :
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ធនាគារជាតិ នៃកម្ពុជា
-អគ្គនាយកដ្ឋានពន្ធដារ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលាខេត្តព្រះសីហនុ
-មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ " មុខការ "
ក.ស.ន-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៣០៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបមក**

លោក JOHN BRINSDEN ប្រធានក្រុមប្រឹក្សាភិបាលនៃ **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
អាសយដ្ឋាន : អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំបង្កើតសាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ACLEDA Bank Plc.

**យោង** : -សំណើរបស់ធនាគារលេខ ធអក ៣៧៥៤/១៤ ចុះថ្ងៃទី ១៥-១២-២០១៤
-សេចក្តីសំរេចរបស់ធនាគារលេខ ធអក ១៥៦៥/១៤ ចុះថ្ងៃទី ២៩-០៥-២០១៤
-អាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារលេខ ធ ០៦-១៦/០៤/០៥/០១ ចុះថ្ងៃទី ១៨-០៣-២០១៤ របស់ធនាគារជាតិនៃកម្ពុជា

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការបង្កើតសាខា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ACLEDA Bank Plc. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. ៥១៨៥KH/២០០០ ចុះថ្ងៃទី ០៥-០៦-២០០០ មួយកន្លែង :

១-នាមករណ៍របស់សាខា : **ធនាគារ អេស៊ីលីដា ភីអិលស៊ី "សាខាស្រុកកូនមុំ - ឃុំត្រពាំងច្រេស"** ACLEDA Bank Plc." Koun Mom District Branch – Trapeang Chres Commune "

២-នាយកសាខា : លោក **ឆោម វ៉ាឌី** "តតិយជន"

៣-ទីស្នាក់ការសាខា : ភូមិ៣ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី ។

៤-កម្មវត្ថុអាជីវកម្ម : -ប្រតិបត្តិការធនាគារ ។

ធនាគារត្រូវសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។
អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុរដ្ឋលេខាធិការ**

ភ្លុយ_ស៊ុជាតិ

**ចម្លងជូន :**

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ធនាគារជាតិ នៃកម្ពុជា
-អគ្គនាយកដ្ឋានពន្ធដារ
-អគ្គនាយកដ្ឋានរាជកិច្ច និងសោភ័ណភាព
-សាលាខេត្តរតនគិរី
-មន្ទីរពាណិជ្ជកម្មខេត្តរតនគិរី "មុខការ"
ក.ស.ឧ-ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០៣១០ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី**១៣ **ខែ**មករា **ឆ្នាំ** ២០១៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមអត្តលេខ Co. ៣៧៨៨E/២០១៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈ ច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វីហ្គ្រូវ ផៅវ័រ ផ្លាស**
**WEGROW POWER PLUS Co., Ltd.**
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក RAKCHAT PEMKHETGRUM
៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦០-៦២ ផ្លូវបុរីសូឡា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្មៈ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាកេការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
- សេវាផ្នែកព័ត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូនៈ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ ។

-ទេសចរណ៍: សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម: ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។ ៚

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ក្មុយ សុជានី**

**ចម្លងជូន:**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០៣១១ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ១៣ **ខែ** មករា **ឆ្នាំ ២០**១៥

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រោមអត្តលេខ **Inv. ៣៨៥៨E/២០១៤** ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៤ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម :

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ស្កាយ ណាយ II អ៊ិនធើណេសិនណាល**<br>**SKY NICE II INTERNATIONAL Co., Ltd.** |
| មានទ្រង់ទ្រាយជា | : | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក CHEN, HUNG-PIN |
| ៣- ដើមទុនក្រុមហ៊ុន | : | ១.០០០.០០០ ដុល្លារអាមេរិក |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | ផ្លូវលំ ភូមិតាសែន ឃុំស្វទិប ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -រោងចក្រផលិតស្បែកជើង ។ |
| ៦- ថិរវេលា | : | ៩៩ ឆ្នាំ |

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**
**ពិទ្ធិភា-ប្រូជា**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកំពង់ចាម
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៣១៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន China Sincerely Leather Group Limited ( ចិន ) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមអត្តលេខ Co. ០០១២E/២០១៥ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៥ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ឆាយណា ស៊ីនសៀរលី លេធើរ គ្រុប (ខេមបូឌា) លីមីធីត**
**China Sincerely Leather Group (Cambodia) Limited**
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក HUAI WANG "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក CHU WANG "តតិយជន" អភិបាល
លោកស្រី PING WANG "តតិយជន" អភិបាល
លោក DING CHEN "តតិយជន" អភិបាល
លោក XINZHOU WANG "តតិយជន" អភិបាល
៣- ដើមទុនក្រុមហ៊ុន : ៤០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៥-២៦ ភូមិឬទ្ធី១ ឃុំកែវផុស ស្រុកស្រែអំបិល ខេត្តព្រះសីហនុ ។
៥- កម្មវត្ថុអាជីវកម្ម : -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ អាហារីណ នីហារីណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ និងសម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
-សេវាកម្មអចលនវត្ថុ និងសេវាកម្មវាយតម្លៃអចលនវត្ថុ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្នែកព័ត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេ CD...

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាកម្រៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម រចនាប្លង់ សិក្សាគម្រោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ង៉ូវ-ប្រុជា**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលាខេត្តព្រះសីហនុ
- មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ "មុខការ"

ម.សរ - ឯកសារ - កាលប្បវត្តិ